# ធនាគារជាតិ នៃ កម្ពុជា

# ព្រឹត្តិបត្រប្រចាំត្រីមាស



# លេខ ៣៦

## ត្រីមាសទី២ ឆ្នាំ២០១១

ចេញផ្សាយតាមប្រកាសលេខ ធ១.០២.១២៦ ប្រ.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ២២-២៤ មហាវិថីព្រះនរោត្តម<br>ភ្នំពេញ កម្ពុជា |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |

*********

Published by

# National Bank of Cambodia

| | | |
|---|---|---|
| Address | : | 22-24 Preah Norodom Blvd.<br>Phnom Penh, Cambodia |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |

| គណៈកម្មការព្រឹត្តិបត្រ | | Review Commission | |
|---|---|---|---|
| - ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | និពន្ធនាយក | H.E. Dr.Sum Sannisith | Chief Editor |

# **អារម្ភកថា**



**ឯកឧត្តម ជា ចាន់តូ**
**ទេសាភិបាលធនាគារជាតិនៃកម្ពុជា**

## *ប្រិយមិត្តអ្នកអានជាទីមេត្រី !*

នៅក្នុងឆ្នាំ២០១១ នេះ សេដ្ឋកិច្ចពិភពលោកទទួលរងសម្ពាធមួយថ្មី ដែលនាំឲ្យសន្ទុះកំណើនមានកម្រិតទាបជាងឆ្នាំ២០១០ ដោយសារវិបត្តិបំណុលសាធារណៈនៅតំបន់អឺរ៉ុបមានសភាពធ្ងន់ធ្ងរនិងក្លាយជាបញ្ហាប្រឈមចំពោះទស្សនាទានសេដ្ឋកិច្ចពិភពលោក ។ ទន្ទឹមនោះ បញ្ហាអតុល្យភាពសេដ្ឋកិច្ចសកលក៏ពុំទាន់មានដំណោះស្រាយសមស្រប ខណៈប្រទេសអភិវឌ្ឍន៍មួយចំនួននៅមានអត្រានិកម្មភាពខ្ពស់ ជំនឿទុកចិត្តរបស់អ្នកវិនិយោគនិងអ្នកប្រើប្រាស់នៅទាប ហើយការស្តារឡើងវិញពីគ្រោះធម្មជាតិពុំទាន់បានបញ្ចប់ជាស្ថាពរ ។

ការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា កំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះពី ៥,១% នៅឆ្នាំ២០១០ មក ៤% នៅឆ្នាំ២០១១ នេះ ក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ដូចជាសហរដ្ឋអាមេរិកមានអត្រាកំណើន ១,៥% និងអឺរ៉ុប ១,៦% ខណៈដែលសេដ្ឋកិច្ចតំបន់អាស៊ីមានមូលដ្ឋានរឹងមាំក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចពិភពលោក ក្នុងនោះ ប្រទេសចិនមានអត្រាកំណើន ៩,៤% ឥណ្ឌា ៧,៨% និង អាស៊ានធំប្រាំ ៥,៣% ទោះបីសេដ្ឋកិច្ចជប៉ុនមានកំណើន -0,៥% ក៏ដោយ ។

ចំពោះប្រទេសកម្ពុជាឆ្នាំ២០១១ បានបង្ហាញលទ្ធផលគួរកត់សម្គាល់ ដោយស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរក្សាស្ថិរភាពយ៉ាងល្អប្រសើរ ទោះបីជាមានផលប៉ះពាល់ពីគ្រោះទឹកជំនន់នៅតំបន់ខ្លះក្តី ។ ស្ថិតក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងនិងការអនុវត្តនយោបាយសារពើពន្ធនិងរូបិយវត្ថុសមស្របរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ៦,៤% ដែលទ្រទ្រង់ដោយការរីកចម្រើននៃវិស័យកសិកម្ម ១,៤% ឧស្សាហកម្ម ១៤,១% (វិស័យកាត់ដេរ ២១%) និងសេវាកម្ម ៥% ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានខិតខំរក្សាស្ថិរភាពថ្លៃតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងទ្រទ្រង់ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ។ សម្ពាធអតិផរណាក្នុងឆ្នាំ២០១១ ស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ដោយមានអត្រាមធ្យមប្រចាំឆ្នាំត្រឹម ៥,៥% ។ ប្រាក់រៀលបានឡើងថ្លៃ ៣,៧% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការកើនឡើងនៃតម្រូវការប្រាក់រៀល ក្នុងសកម្មភាពសេដ្ឋកិច្ចនិងកំណើនលំហូរចូលនៃដើមទុនមកក្នុងប្រទេស ក្នុងនោះវិនិយោគផ្ទាល់បរទេសមានទំហំប្រមាណ ៦៩២ លានដុល្លារអាមេរិក ។ ជារួម ក្នុងអំឡុងមួយទសវត្សរ៍នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពល្អប្រសើរ ដែលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារនិងសេដ្ឋកិច្ចជាតិ ។

បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជាមានការអភិវឌ្ឍជាលំដាប់ ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ។

នៅឆ្នាំ២០១១ នេះ សាខាធនាគារបរទេសខ្នាតអន្តរជាតិចំនួន ៣ បានទទួលអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារនៅកម្ពុជា ។ បណ្តាញសាខារបស់គ្រឹះស្ថានធនាគារបានកើនឡើងពី ៣៦១ នៅឆ្នាំ ២០១០ ដល់ ៤០៧ នៅឆ្នាំ ២០១១ ។ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ និងឥណទានចំពោះវិស័យឯកជនបានកើនឡើង ២០% និង ២៨% រៀងគ្នា ធៀបឆ្នាំ២០១០ ហើយវិស័យដែលមានកំណើនឥណទានខ្ពស់ជាងគេ គឺកសិកម្ម ៥៤% ឧស្សាហកម្ម ៣៧% និងសំណង់ ៣៦% ។ លទ្ធផលនេះបានបង្ហាញនូវការយកចិត្តទុកដាក់នៃវិស័យធនាគារក្នុងការលើកកម្ពស់វិស័យកសិកម្មស្របតាមការចង្អុលទិសដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ។ គ្រឹះស្ថានធនាគារមានសុខភាពរឹងមាំ ដែលឆ្លុះបញ្ចាំងដោយអនុបាតសាធនភាពជាមធ្យមក្នុងកម្រិតប្រមាណ ២៨,៦% អនុបាតសាច់ប្រាក់ងាយស្រួល (សន្ទនីយភាព) ៨៧% និងអនុបាតឥណទានមិនដំណើរការ ៣,៣% ។ កម្មវិធីបង្កើនដើមទុនអប្បបរមាចំពោះគ្រឹះស្ថានធនាគារក៏ត្រូវបានបញ្ចប់ដោយជោគជ័យ ។

សមិទ្ធផលដ៏សំខាន់មួយនៅក្នុងឆ្នាំ២០១១នេះ ចំពោះវិស័យហិរញ្ញវត្ថុ គឺការអនុម័តរបស់រាជរដ្ឋាភិបាលកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ លើឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ។ ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាងធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ព្រមទាំងគណៈកម្មការមូលបត្រកម្ពុជានិងក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីជាមូលដ្ឋានក្នុងការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិនិងតំបន់។

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារយ៉ាងយកចិត្តទុកដាក់សំដៅជំរុញប្រតិបត្តិការធនាគារឲ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាពនិងសុវត្ថិភាព តាមរយៈការលើកកម្ពស់ការត្រួតពិនិត្យនិងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិនានា ។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏មានការរីកចម្រើនជាលំដាប់និងមានបណ្តាញសេវាទូលំទូលាយដល់ជនបទ ។ វិស័យនេះបានដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ ឥណទានមីក្រូហិរញ្ញវត្ថុបានកើន ដល់ ២.២៩៧ ពាន់លានរៀល មានកំណើន ៣៣% ធៀបនឹងឆ្នាំកន្លងទៅ ខណៈចំនួនអតិថិជនបានកើន ដល់ជាង១លាននាក់ ។

ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី៤ថ្នាក់ទេសាភិបាលរងអាស៊ានផ្នែកសមាហរណកម្មវិស័យហិរញ្ញវត្ថុ កិច្ចប្រជុំប្រចាំឆ្នាំថ្នាក់នាយកប្រតិបត្តិស៊ាសិនលើកទី៩ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេស និយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) លើកទី១៨ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមវិភាគទាននិងសហការយ៉ាងជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជាក្នុងការសម្រេចបាននូវភារកិច្ចជាបន្តបន្ទាប់ ។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមប្រកបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ចនិងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**

# មាតិកា

ទំព័រ


➢ អារម្ភកថា ........................................................................................... i-ii

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិ នៃកម្ពុជា ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា............................................ ១

➢ សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិ នៃកម្ពុជា ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា............................................ ១១

➢ ប្រកាស ស្តីពីការចេញផ្សាយមូលបត្រអាចជួញដូរបាន ដោយធនាគារជាតិ នៃកម្ពុជា........................................................................................... ២០

➢ ប្រកាស ស្តីពីការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និង ទស្សនៈអនាគត........................................................................................... ៣២

➢ វិបត្តិបំណុលសាធារណៈប្រទេសក្រិច និងឥទ្ធិពលរបស់វាទៅលើសេដ្ឋកិច្ចពិភពលោក........................................................................................... ៣៦

➢ តារាងអត្រាប្តូរប្រាក់ប្រចាំខែ ........................................................................ ៤៤

➢ តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ ................................................................ ៤៥

➢ តារាងអត្រាការប្រាក់លើប្រាក់កម្ចី .................................................................. ៤៧

➢ បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ.......................................................... ៤៩

➢ បញ្ជីឈ្មោះមីក្រូហិរញ្ញវត្ថុបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា....................... ៧៦

➢ ប្រព័ន្ធធនាគារកម្ពុជា .................................................................................. ៧៨

➢ រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិ នៃ កម្ពុជា........................................ ៨០-៩៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ...........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា
## ថ្ងៃទី១០-១១ ខែសីហា ឆ្នាំ២០១១ នៅធនាគារជាតិនៃកម្ពុជា

**សូមគោរព :**

**- គណៈអធិបតី**

**- លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីស្នេហា**

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយជាអតិបរមា ដោយបានមកចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា ជាមួយ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា នាពេលនេះ ។ ជារៀងរាល់ឆ្នាំ យើងតែងតែរៀបចំប្រារព្ធពិធីនេះឡើងដើម្បីផ្សព្វផ្សាយនិងអបអរសាទរចំពោះលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងដើម្បីបង្កបរិយាកាសឱ្យមន្ត្រីបុគ្គលិករបស់យើងទាំងនៅទីស្នាក់ការកណ្តាល និងនៅសាខារាជធានី-ខេត្ត បានជួបប្រាស្រ័យទាក់ទងគ្នាជាបណ្តាញការងារ និងរាប់អានគ្នាកាន់តែជិតស្និទ្ធថែមទៀត ។

ទន្ទឹមពេលនេះ ខ្ញុំសូមថ្លែងអំណរគុណនិងកោតសរសើរយ៉ាងខ្លាំងចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវ បានរួមចំណែកកសាងសមិទ្ធផលជាច្រើនជូនធនាគារជាតិនៃកម្ពុជា និងរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យមានសុវត្ថិភាព ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបថា សន្និបាតរបស់យើងថ្ងៃនេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយពីលទ្ធផលការងារឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា ដូចតទៅ ៖

## I/- សភាពការណ៍ទូទៅនៃសេដ្ឋកិច្ចពិភពលោក តំបន់ និងសេដ្ឋកិច្ចកម្ពុជា

នៅឆមាសទី១ ឆ្នាំ២០១១ នេះ ពិភពលោកបានប្រឈមនឹងបញ្ហាធំៗមួយចំនួន ដូចជា *១/-* បញ្ហាសម្ពាធអតិផរណាខ្ពស់ដោយសារការកើនឡើងនៃថ្លៃស្បៀងអាហារ ការដឹកជញ្ជូន ផ្ទះសម្បែង និងការខូចខាតទិន្នផលកសិកម្មនៅចុងឆ្នាំ២០១០ *២/-* វិបត្តិគ្រោះធម្មជាតិនៃការរញ្ជួយដីនិងរលកយក្សស៊ូណាមិ *៣/-* អត្រានិកម្មភាពនៅតែមានកម្រិតខ្ពស់ *៤/-* ការគរពូនបំណុលសាធារណៈកម្រិតខ្ពស់ ជាបន្ទុកដ៏ធ្ងន់ធ្ងរចំពោះប្រជាជន/គ្រឹះស្ថានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ *៥/-* ការបន្តអនុវត្តនយោបាយរូបិយវត្ថុបន្ធូរបន្ថយយូរពេក កំពុងគំរាមកំហែងដល់ស្ថិរភាពថ្លៃ *៦/-* ការកើនឡើងនៃថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិ ដោយសារតម្រូវការប្រេងកើនឡើងបន្ទាប់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក និងភាពវឹកវរនៅពិភពអារ៉ាប់និងអាហ្វ្រិកខាងជើង ដែលជាអ្នកផលិតប្រេងនាំចេញ *៧/-* ការកើនឡើងនៃកំណើនឥណទានចូលទៅក្នុងសេដ្ឋកិច្ចលឿនពេក និង *៨/-* បញ្ហាអស្ថិរភាពនិងភាពមិនពិតប្រាកដផ្នែកនយោបាយក្នុងតំបន់មានរយៈពេលយូរពេក ។

បញ្ហាទាំងនេះបានផ្តល់ការលំបាក និងការគំរាមកំហែងដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ។ បញ្ហានេះតម្រូវឱ្យអ្នករៀបចំគោលនយោបាយ អ្នកសម្រេចចិត្តផ្នែកនយោបាយ និងអ្នកដឹកនាំស្ថាប័នហិរញ្ញវត្ថុ បន្តយកចិត្តទុកដាក់ពង្រឹងកម្មវិធីកំណែទម្រង់បន្ថែមទៀត ។ បន្ទាប់ពីអាជ្ញាធរនៃប្រទេសក្នុងតំបន់បានចាត់វិធានការទាន់ពេលវេលានិងមានប្រសិទ្ធភាពរួចមក ឃើញថាសេដ្ឋកិច្ចពិភពលោកកំពុងឈានទៅរកកំណើនប្រកបដោយចីរភាពដោយខ្លួនឯង ។ ប្រទេសកំពុងអភិវឌ្ឍន៍មានកំណើនរឹងមាំ និងប្រទេសអភិវឌ្ឍន៍កំពុងមានកំណើនងើបឡើងវិញជាបណ្តើរៗ ។ ដោយឡែកសេដ្ឋកិច្ចអាស៊ីគឺមានមូលដ្ឋានគ្រឹះរឹងមាំ ដូចជា ប្រទេសចិន ឥណ្ឌា និងឥណ្ឌូណេស៊ី ហើយបានដើរតួសំខាន់ជាងគេនិងនាំមុខក្នុងការជំរុញកំណើនសេដ្ឋកិច្ចពិភពលោក ។

តាមការព្យាកររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) នៅឆមាសទី១ ឆ្នាំ២០១១ នេះ សេដ្ឋកិច្ចពិភពលោកត្រូវបានប៉ាន់ស្មានថា មានកំណើន ៤,៣% ធៀបនឹង ៥,៥% ក្នុងឆ្នាំ២០១០ ។ ប្រទេសអភិវឌ្ឍន៍រំពឹងថានឹងមានកំណើនសេដ្ឋកិច្ចក្នុងកម្រិត ២,២% និងអត្រាអតិផរណា ២,៦% ខណៈដែលបណ្តាប្រទេសកំពុងងើបឡើងនិងកំពុងអភិវឌ្ឍន៍មានកំណើន ៦,៦% និងអត្រាអតិផរណា ៦,៩% ។ ចំណែកឯប្រទេសចិនត្រូវបានរំពឹងថាមានកំណើន ៩,៦% ឥណ្ឌា ៨,២% និងប្រទេសអាស៊ានធំ៥ មានកំណើន ៥,៤% ។

ដោយឡែក សេដ្ឋកិច្ចកម្ពុជាបានបន្តកើនឡើងក្នុងល្បឿនមួយគួរឱ្យកត់សម្គាល់ ។ តាមការព្យាករដោយប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាលរំពឹងថា នៅឆ្នាំ២០១១ នេះ កំណើនសេដ្ឋកិច្ចនឹងកើនឡើងពី ៦ ទៅ ៧% ធៀបនឹងឆ្នាំ២០១០ មានកម្រិតជាង ៦% លើសពីការ

រំពឹងទុក ។ កំណើននេះទ្រទ្រង់ដោយសារភាពអំណោយផលពីវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស ។ ចំណែកឯអត្រាអតិផរណានៅឆ្នាំ២០១១ ត្រូវបានរំពឹងថានឹងស្ថិតក្នុងកម្រិតមួយខ្ទង់អាចគ្រប់គ្រងបាន ។

## II/- លទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន

នៅក្នុងឆមាសទី១ ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានខិតខំបំពេញតួនាទីរបស់ខ្លួនក្នុងការរក្សាស្ថិរភាពថ្លៃប្រកបដោយប្រសិទ្ធភាព តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ន ដើម្បីរួមចំណែកពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចសំដៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។ សមិទ្ធផលទាំងនេះអាចឆ្លុះបញ្ចាំងតាមរយៈសូចនាករដូចខាងក្រោម ៖

ជារួម ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅតែរក្សាស្ថិរភាពល្អប្រសើរនៃកំណើនជាប់ជាប្រចាំ ទោះបីជាអត្រាអតិផរណាបានកើនឡើងបន្តិចក៏ដោយ ក៏តម្លៃប្រាក់រៀលមានស្ថិរភាពល្អប្រសើរ ។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារបានឡើងថ្លៃប្រមាណ ៤% ធៀបនឹងខែមិថុនា នៅឆ្នាំ២០១០ និងចុះថ្លៃ ១,១% ធៀបនឹងខែធ្នូ ឆ្នាំ២០១០ ។ ស្ថិរភាពថ្លៃនិងតម្លៃប្រាក់រៀលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនទូទៅចំពោះសេដ្ឋកិច្ចកម្ពុជា ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងរហូតដល់ ២.៩១២,៧ លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបានចំនួនប្រមាណ ៤ខែ ។ ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ យើងអនុវត្តដោយឈរលើមូលដ្ឋានប្រុងប្រយ័ត្ន គឺសុវត្ថិភាពនិងសាច់ប្រាក់ងាយស្រួលជាចម្បង ។

ក្រៅពីការចូលរួមពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ធនាគារជាតិនៃកម្ពុជាបានរួមចំណែកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ហើយសម្រេចបានលទ្ធផលល្អប្រសើរដូចខាងក្រោម ៖

**១/-វិស័យធនាគារ** : មានភាពរឹងមាំ មានសុវត្ថិភាព និងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ហើយបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ផ្នែកវិសាលភាព ធនាគារពាណិជ្ជមានចំនួន ២៩ ធនាគារឯកទេសចំនួន ៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២៧ ។ ជាក់ស្តែង ថ្មីៗនេះមានធនាគារខ្នាតអន្តរជាតិចំនួនបីបានមកបើកសាខារបស់ខ្លួននៅកម្ពុជា គឺធនាគារកសិកម្មនិងអភិវឌ្ឍន៍វៀតណាម (Agri Bank) ធនាគារ CIMB ម៉ាឡេស៊ី និងធនាគារចិន (Bank of China) ។ សូចនាករនេះបានបង្ហាញពីការកើនឡើងនៃជំនឿទុកចិត្ត និងការគាំទ្ររបស់វិនិយោគិនបរទេសមកលើទីផ្សារធនាគារនិងសេដ្ឋកិច្ចកម្ពុជាថែមទៀត។

ចំពោះទំហំប្រតិបត្តិការវិញ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារបានកើនឡើងចំនួន ២៥,៩៥% និងឥណទានដល់វិស័យឯកជនបានកើនឡើងចំនួន ៣១,៦% ធៀបនឹងគ្រាដូចគ្នានៅឆ្នាំ២០១០ ។ អ្នកផ្ញើប្រាក់មានចំនួន ១.១៧៣.៤៤៦ នាក់ និងអ្នកខ្ចីឥណទានមានចំនួន ២៨៥.៨៥៥ នាក់ ។ ការវិវត្តរីកចម្រើននេះគួបផ្សំនឹងការអនុវត្តវិធានការប្រុងប្រយ័ត្នផងនោះ បានធ្វើឱ្យឥណទានមិនដំណើរការ (NPL) ថយចុះជាលំដាប់មកត្រឹម ៣,១៥% នៃកញ្ចប់ឥណទានសរុប ។

**២/- វិស័យមីក្រូហិរញ្ញវត្ថុ** : មានការរីកចម្រើនយ៉ាងខ្លាំង និងមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំដល់ជនបទ ។ វិស័យនេះត្រូវបានគេចាត់ទុកថា ជាវិស័យគន្លឹះក្នុងការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជានៅជនបទនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ ឥណទាននៃវិស័យមីក្រូហិរញ្ញវត្ថុបានកើនឡើងគួរឱ្យកត់សម្គាល់ ដោយចំនួនអតិថិជនបានកើនឡើងដល់ ១.០១៩.៤១១ នាក់ និងឥណទានសរុបមានចំនួន ២.១២១ ពាន់លានរៀល គឺកើនឡើងប្រមាណ ១២% ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំ២០១០ ។ ប្រាក់បញ្ញើវិញមានចំនួន ២៧៣ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ២៦១.៦៦១ នាក់ ។ អនុបាតឥណទានមិនដំណើរការមានចំនួនតែ ១,៣% ប៉ុណ្ណោះ គិតត្រឹមដំណាច់ឆមាសទី១ នេះ ។

ការរីកចម្រើននេះបានរួមចំណែកអភិវឌ្ឍអាជីវកម្មធុនតូចនិងមធ្យម និងវិស័យកសិកម្មនៅកម្ពុជា ។ វឌ្ឍនភាពនេះបានបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាកាន់តែមានការយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងស្គាល់ពីវប្បធម៌ឥណទានកាន់តែប្រសើរឡើង ។

**៣/- ការងារត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ** : ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យយើងបានសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ចុះទៅត្រួតពិនិត្យដល់ទីកន្លែងនិងត្រួតពិនិត្យលើឯកសារ ដើម្បីជួយពង្រឹងអភិបាលកិច្ចល្អនិងភាពរឹងមាំរបស់គ្រឹះស្ថានធនាគារ ។ គិតត្រឹមឆមាសទី១ ធនាគារជាតិនៃកម្ពុជាបានបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះធនាគារពាណិជ្ជចំនួន ១០ ធនាគារឯកទេសចំនួន ៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ១០ និងប្រតិបត្តិករឥណទានជនបទចំនួន ២ ។

ជារួម ស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារមានភាពល្អប្រសើរ និងគោរពតាមវិធានការប្រុងប្រយ័ត្ន ។ ចំពោះគ្រឹះស្ថានធនាគារមួយចំនួនដែលមានចំណុចខ្វះខាត យើងបានផ្តល់អនុសាសន៍ដើម្បីកែតម្រូវ និងមានវិធានការដោះស្រាយតាមស្ថានភាពជាក់ស្តែងផងដែរ ។

**៤/- ការធ្វើកំណែទម្រង់រចនាសម្ព័ន្ធ និងការពង្រឹងអភិបាលកិច្ចល្អ** : បន្ទាប់ពីបានពិនិត្យឃើញពីតម្រូវការចាំបាច់នៃការងារ ការវិវត្តរីកចម្រើននៃវិស័យធនាគារ និងឆ្លើយតបទៅនឹងនិន្នាការរបស់ប្រទេសក្នុងតំបន់ ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជាបានសម្រេចធ្វើកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងធនាគារជាតិនៃកម្ពុជា និងធ្វើវិសោធនកម្មប្រកាសស្តីពីរចនាសម្ព័ន្ធរបស់

ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ ដោយបង្កើតឱ្យមានអគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានត្រួតពិនិត្យ និងនាយកដ្ឋានមួយចំនួនទៀតនៅក្រោមឱវាទ ដើម្បីបែងចែកមុខងារ-ភារកិច្ចជាលក្ខណៈបច្ចេកទេសឱ្យច្បាស់លាស់ តួនាទីអ្នកត្រួតពិនិត្យ បញ្ញត្តិករ និងអ្នកគ្រប់គ្រងគោលនយោបាយរូបិយវត្ថុ ស្របតាមការអនុវត្តជាអន្តរជាតិ និងការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចជាតិនាពេលបច្ចុប្បន្ន ។

**ការពង្រឹងអភិបាលកិច្ចល្អ** : ក្រៅពីការងារកែសម្រួលក្របខ័ណ្ឌបទប្បញ្ញត្តិ និងវិធានការប្រុងប្រយ័ត្នមួយចំនួន ឱ្យស្របតាមយន្តការទីផ្សារនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានពង្រឹងការងារសវនកម្មផ្ទៃក្នុង និងការងារអធិការកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយបានបំពាក់ប្រព័ន្ធព័ត៌មានវិទ្យា និងបានលើកកម្ពស់សមត្ថភាពត្រួតពិនិត្យផ្ទៃក្នុងសម្រាប់មន្ត្រីបុគ្គលិកបណ្តាសាខាធនាគារជាតិនៃកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ។ មន្ត្រីជំនាញយើងបានចុះធ្វើសវនកម្មនៅសាខាធនាគារជាតិនៃកម្ពុជាខេត្តស្វាយរៀង កំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ បន្ទាប់ពីបានធ្វើសវនកម្មរួច យើងក៏បានផ្តល់អនុសាសន៍មួយចំនួនដើម្បីកែលម្អចំណុចខ្វះខាតរួចហើយដែរ ។

ចំពោះការងារអធិការកិច្ចវិញ យើងបានចុះឆ្មក់ត្រួតពិនិត្យដោយមិនជូនដំណឹងជាមុននៅសាខាធនាគារជាតិនៃកម្ពុជាបានចំនួន៧ ផ្តោតទៅលើការងារគ្រប់គ្រងសុវត្ថិភាពឃ្លាំងប្រាក់ ការគ្រប់គ្រងសាច់ប្រាក់ និងបានផ្តល់អនុសាសន៍ណែនាំដើម្បីពង្រឹងគុណវុឌ្ឍិ វិន័យការងារមន្ត្រីបុគ្គលិក និងប្រសិទ្ធភាពការងារនៅតាមសាខាឱ្យកាន់តែប្រសើរ ។ ជាលទ្ធផល យើងពិនិត្យឃើញថា ប្រតិបត្តិការធនាគារជាតិនៃកម្ពុជាត្រូវបានពង្រឹង និងប្រព្រឹត្តទៅដោយរលូន និងមានលក្ខណៈល្អប្រសើរ ។

**៥/- ការអភិវឌ្ឍទីផ្សារអន្តរធនាគារ** : ជាការងារអាទិភាពរបស់យើង ។ ដើម្បីអភិវឌ្ឍទីផ្សារអន្តរធនាគារនិងទីផ្សារមូលបត្រនៅកម្ពុជា ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាបានរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិមួយចំនួន ដើម្បីធ្វើមូលបត្រនីយកម្មប្រាក់បញ្ញើមានកាលកំណត់របស់គ្រឹះស្ថានធនាគារនៅធនាគារជាតិនៃកម្ពុជា ។ ក្នុងខណៈដែលទីផ្សារមូលបត្រនិងទីផ្សារទុននៅកម្ពុជាត្រូវបានបង្កើតឡើងក្នុងពេលថ្មីៗនេះ យើងក៏បានកំពុងបណ្តុះបណ្តាលមន្ត្រីជំនាញ និងផ្សព្វផ្សាយឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុយល់ដឹងពីសារៈសំខាន់និងផលប្រយោជន៍នៃការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនេះ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងពិចារណាអំពីការបោះផ្សាយឧបករណ៍ឥណទានរយៈពេលខ្លី ដែលអាចជួញដូរបានក្នុងពេលសមស្របខាងមុខនេះ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុនិងសេដ្ឋកិច្ចជាតិ ។

**៦/- ការពង្រឹងក្របខ័ណ្ឌច្បាប់និងការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់** : ក្រោមជំនួយឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារជាតិនៃកម្ពុជាយើងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់ និងអភិវឌ្ឍប្រព័ន្ធនេះដើម្បីសម្រួលដល់ការទូទាត់ឱ្យកាន់តែសម្បូរបែប និងមានប្រសិទ្ធភាពក្នុងការទូទាត់ពាណិជ្ជកម្មថែមទៀត ។ ដើម្បីសម្រួលប្រតិបត្តិការទូទាត់ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្តីពីអ្នកដំណើរការតតិយភាគី និងប្រកាសស្តីពីការដាក់ឱ្យប្រើគំរូបញ្ជាទូទាត់ សម្រាប់ការផ្ទេរតេណទាន ។

ប្រកាសនេះ គឺជាក្របខ័ណ្ឌគតិយុត្តមួយសម្រាប់គ្រប់គ្រងក្រុមហ៊ុន ឬគ្រឹះស្ថានមិនមែនធនាគារ រួមទាំងក្រុមហ៊ុនទូរស័ព្ទចល័តដែលធ្វើជាអ្នកដំណើរការតតិយភាគីក្នុងការផ្តល់សេវាផ្ទេរប្រាក់ ឬសេវាទូទាត់ផ្សេងៗទៀត ធ្វើប្រតិបត្តិការរបស់ខ្លួនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។

**៧/- ការពង្រឹងការប្រើប្រាស់ប្រាក់រៀល** : រាជរដ្ឋាភិបាលបានសម្រេចលើកកម្ពស់និងជំរុញការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ ក្នុងបំណងឈានទៅធ្វើបដិដុល្លារូបនីយកម្មពីសេដ្ឋកិច្ចជាតិ ក្នុងខណៈពេលដែលទីផ្សារមូលបត្រនិងទីផ្សារទុនត្រូវបានបង្កើតឡើង ។ បញ្ហាដុល្លារូបនីយកម្មនៅកម្ពុជាមិនមែនកើតឡើង ដោយសារការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលទេ គឺដោយសារប្រវត្តិសាស្ត្របានបន្សល់ទុក ហើយបានក្លាយទៅជាបញ្ហារួមរបស់យើងទាំងអស់ បន្ទាប់ពីជំនឿទុកចិត្តរបស់សាធារណជនទូទៅមកលើប្រាក់រៀលបានធ្លាក់ចុះក្រោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ។

ដុល្លារូបនីយកម្មនៅកម្ពុជាបាននាំមកនូវគុណសម្បត្តិផងនិងគុណវិបត្តិផង ប៉ុន្តែគុណវិបត្តិមានច្រើនជាងគុណសម្បត្តិចំពោះសេដ្ឋកិច្ចនិងសង្គម ។ បញ្ហានេះបានក្លាយទៅជាបញ្ហាប្រឈមចំពោះការអនុវត្តគោលនយោបាយរូបិយវត្ថុ ដែលតម្រូវឱ្យអាជ្ញាធរជាអ្នករៀបចំគោលនយោបាយ និងថ្នាក់ដឹកនាំស្ថាប័នហិរញ្ញវត្ថុ ត្រូវមានឆន្ទៈច្បាស់លាស់ក្នុងការរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រច្បាស់លាស់ និងការចូលរួមពីសាធារណជនទូទៅដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះ ។

**៨/- ការពង្រឹងប្រតិបត្តិការសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : ដើម្បីបន្តអនុវត្តតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត យើងបានកំណត់សាខាដែលមានអាទិភាព និងមានសក្តានុពលផ្នែកសេដ្ឋកិច្ចដើម្បីកែលម្អ ។ ធនាគារជាតិនៃកម្ពុជាបានខិតខំពង្រឹងប្រតិបត្តិការផ្ទៃក្នុងរបស់ខ្លួនតាមរយៈការកែលម្អកន្លែងធ្វើការ បំពាក់ប្រព័ន្ធព័ត៌មានវិទ្យាដើម្បីឱ្យឆ្លើយតបតាមតម្រូវការការងារ ការបណ្តុះបណ្តាលផ្នែកការងារប្រតិបត្តិការនិងជំនាញ IT និងរៀបចំការងារចាត់តាំងមន្ត្រីបុគ្គលិកនៅតាមសាខារាជធានី-ខេត្ត ស្របតាមការងារជាក់ស្តែង ។

យើងបានដាក់ឱ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល (CBS) និងការបណ្តុះបណ្តាលធនធានមនុស្ស ទាំងផ្នែកបច្ចេកទេសនិងការងារគ្រប់គ្រងត្រូវបានពង្រឹង ដើម្បីឱ្យប្រតិបត្តិការរបស់យើងកាន់តែទូលំទូលាយ ស៊ីជម្រៅ និងមានព័ត៌មានត្រូវគ្នារវាងទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ចំពោះព័ត៌មានដូចគ្នា ។ រហូតមកដល់ពេលនេះ ការងារនេះយើងបានអនុវត្តដោយរលូននិងមានប្រសិទ្ធភាព ។

**៩/- ការងារសមាគមមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា** : កាន់តែរីកចម្រើន បានបំពេញភារកិច្ចល្អប្រសើរ និងបានជួយរួមចំណែកសម្រាលការលំបាករបស់មន្ត្រីបុគ្គលិករបស់យើងមួយចំនួន ។ ជាក់ស្តែង ទំហំនៃការលំបាករបស់មន្ត្រីបុគ្គលិកយើងមានលក្ខណៈខុសគ្នាពីម្នាក់ទៅម្នាក់ ពីមួយករណីទៅមួយករណី ដូច្នេះសមាគមត្រូវពិនិត្យលទ្ធភាពជាក់ស្តែងបន្ថែមទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិជាលក្ខណៈទ្វេភាគីនិងពហុភាគីវិញ ធនាគារជាតិនៃកម្ពុជាមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ ហើយសម្រេចបានសមិទ្ធផលដូចតទៅ ៖

**១/- មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)** : ក្រុមបេសកកម្មមូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញបេសកកម្មនៅធនាគារជាតិនៃកម្ពុជាចំនួនពីរលើក ដែលលើកទី១ ចាប់ពីថ្ងៃទី២១-២៨ ខែមីនា ឆ្នាំ២០១១ ស្តីពីការវាយតម្លៃជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា និងលើកទី២ នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១១ ស្តីពីស្ថានភាពសេដ្ឋកិច្ច និងពិភាក្សាគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដោយផ្តោតសំខាន់លើស្ថិរភាពហិរញ្ញវត្ថុកម្ពុជា ។

ជារួម អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិបានវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនានាដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ ។ IMF បានបញ្ជូនលោក Faisal Ahmed ធ្វើជាតំណាងរបស់ IMF ប្រចាំនៅប្រទេសកម្ពុជា ជំនួសលោក Milan Zavadjil និងបានបន្តផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដើម្បីតាមដានស្ថិរភាពហិរញ្ញវត្ថុនិងពង្រឹងប្រសិទ្ធភាពការត្រួតពិនិត្យគ្រឹះស្ថានធនាគារថែមទៀត ។

**២/- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)** : បានកោតសរសើរចំពោះរាជរដ្ឋាភិបាល និយាយជារួម និងនិយាយដោយឡែក ចំពោះធនាគារជាតិនៃកម្ពុជាដែលបានដើរតួនាទីស្នូលក្នុងការអនុវត្តគម្រោងការងារនៅក្នុងអនុកម្មវិធីទី៤ ដោយរលូន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ។ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ជំនួយបច្ចេកទេសដើម្បីរៀបចំអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ និងធ្វើបច្ចុប្បន្នកម្មផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ

ហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ឱ្យទៅជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ របស់រាជរដ្ឋាភិបាល ដើម្បីរំកិលទៅអនុវត្តកម្មវិធីយុទ្ធសាស្ត្រដែលនៅសេសសល់ និងបន្តទៅអនុវត្តផែនការយុទ្ធសាស្ត្រថ្មីបន្តទៀត ស្របតាមយន្តការទីផ្សារនិងការវិវត្តរីកចម្រើននៃសេដ្ឋកិច្ចនៅក្នុងតំបន់និងពិភពលោក ។

ឯកសារនេះមានសារៈសំខាន់ណាស់សម្រាប់ប្រទេសកម្ពុជា ព្រោះជាឯកសារយុទ្ធសាស្ត្រសម្រាប់ធ្វើជាមាគ៌ាចង្អុលទិសអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែស៊ីជម្រៅ និងមានកម្រិតសមាហរណកម្មខ្ពស់ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

**៣/- ក្រុមប្រទេសអាស៊ាន (ASEAN)** : ប្រតិភូធនាគារជាតិនៃកម្ពុជាបានចូលរួមជាប្រចាំក្នុងកិច្ចប្រជុំថ្នាក់នយោបាយ និងបច្ចេកទេសសំខាន់ៗរបស់អាស៊ាននិងអាស៊ានបូកបី ដែលពង្រឹងកិច្ចសហប្រតិបត្តិការតាមដានស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងតំបន់ អនុវត្តផែនទីមគ្គុទ្ទេសក៍នៃសមាហរណកម្មរូបិយវត្ថុ-ហិរញ្ញវត្ថុអាស៊ាន ពង្រឹងទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ និងអនុវត្តយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ។

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលរងនិងអនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ (ASEAN Deputies) លើកទី៤ នៅទីក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីជំរុញការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុនិងរូបិយវត្ថុអាស៊ានស្របតាមផែនការយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០១៥ ។

**៤/- មជ្ឈមណ្ឌល SEACEN** : យើងបានទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃមជ្ឈមណ្ឌលស៊ាសិន (SEACEN-EXCO) លើកទី៩ កាលពីថ្ងៃទី១៩-២១ ខែមករា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ និងបានបញ្ជូនមន្ត្រីជំនាញជាបន្តបន្ទាប់ឱ្យចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំសំខាន់ៗនានា នៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការស៊ាសិន ។

កាលពីថ្ងៃទី២៤-២៦ ខែកុម្ភៈ ឆ្នាំ២០១១ ប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាល SEACEN លើកទី៤៦ និងកិច្ចប្រជុំក្រុមប្រឹក្សាទេសាភិបាល SEACEN លើកទី៣០ នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ។ ពេលនោះ ក្នុងនាមជាប្រធានក្រុមប្រឹក្សាទេសាភិបាល SEACEN និងគណៈកម្មាធិការប្រតិបត្តិ SEACEN ធនាគារជាតិនៃកម្ពុជាបានចរចានិងសម្របសម្រួលឱ្យធនាគារកណ្តាលចិនប្រជាមានិត (PBC) បានចូលជាសមាជិកពេញសិទ្ធិទី១៧ របស់ SEACEN បានដោយជោគជ័យ ។ យើងក៏បានប្រគល់តួនាទីជាប្រធានក្រុមប្រឹក្សាទេសាភិបាលនិងគណៈកម្មាធិការប្រតិបត្តិ SEACEN ជូនទៅទេសាភិបាលធនាគារកណ្តាលស្រីលង្កាផងដែរ ។

**៥/- កិច្ចប្រជុំធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone)** : ប្រតិភូធនាគារជាតិនៃកម្ពុជាតែងតែបានទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់ធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) ជារៀងរាល់ឆ្នាំ ។ កាលពីថ្ងៃទី១១-១៣ ខែឧសភា ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំ Francophone នេះ លើកទី១៨ នៅខេត្តសៀមរាប ដើម្បីពិភាក្សាអំពីតួនាទីធនាគារកណ្តាល បញ្ហាប្រឈម និងដំណោះស្រាយចំពោះវិបត្តិ ។ កិច្ចប្រជុំនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រទេសជាតិយើង ព្រោះបានបង្ហាញពីកិច្ចសហប្រតិបត្តិការរបស់កម្ពុជា និងមុខមាត់កម្ពុជាក្នុងក្របខ័ណ្ឌតំបន់និងអន្តរជាតិ ។

**៦/- កិច្ចសហប្រតិបត្តិការទ្វេភាគី** : យើងបានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃ កូរ៉េ បារាំង វៀតណាម ឡាវ ម៉ាឡេស៊ី លុចហ្សំបួរ អាល្លឺម៉ង់ និងធនាគារកណ្តាលនៃបណ្តាប្រទេសអាស៊ានមួយចំនួនទៀត ។ កាលពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១១ ប្រតិភូធនាគារជាតិនៃកម្ពុជាបានទៅចូលរួមប្រជុំទ្វេភាគីជាមួយធនាគារកណ្តាលម៉ុងហ្គោលីក្នុងគោលបំណងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនិងផ្លាស់ប្តូរបទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍធនធានមនុស្ស ។ ជារួម កិច្ចសហប្រតិបត្តិការទ្វេភាគីរបស់យើងត្រូវបានពង្រឹងនិងមានការវិវត្តរីកចម្រើនជាលំដាប់ ទាំងផ្នែកសហប្រតិបត្តិការមិត្តភាព ផ្នែកបច្ចេកទេស ការត្រួតពិនិត្យធនាគារឆ្លងដែន និងការផ្លាស់ប្តូរព័ត៌មានស្តីពីធនាគារនិងសេដ្ឋកិច្ច ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

សរុបមក សមិទ្ធផលទាំងឡាយដែលយើងមានសព្វថ្ងៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងការចូលរួមសហការពីក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ។ ដើម្បីជ្រាបពីសមិទ្ធផលលម្អិតផ្សេងទៀត សូមអង្គសន្និបាតមេត្តាត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំរបស់យើង ដែលនឹងរាយការណ៍លម្អិតជូនអង្គសន្និបាតក្នុងពេលបន្តិចទៀតនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហការ និងការខិតខំប្រឹងប្រែងរបស់សមាជិកក្រុមប្រឹក្សាភិបាលនិងមន្ត្រីបុគ្គលិកទាំងអស់ ដែលបានរួមចំណែកកសាងធនាគារជាតិនៃកម្ពុជាឱ្យទទួលបានលទ្ធផលល្អប្រសើរគួរជាទីមោទនៈ ។ ខ្ញុំនៅតែមានជំនឿជឿជាក់ថា លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា នៅតែបន្តស្មារតីសាមគ្គីគ្នាជាប្រពៃណីនេះតទៅទៀត ។ អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅរយៈពេលពីរថ្ងៃ សូមលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ខិតខំស្តាប់របាយការណ៍ស្តីពីលទ្ធផលការងារដែលអនុវត្តកន្លងមក និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ ដើម្បីយកទៅអនុវត្តការងាររបស់ខ្លួនឱ្យបានជោគជ័យនិងមានប្រសិទ្ធភាព ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់ លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញា ដែលមានវត្តមាននៅក្នុងអង្គសន្និបាតនេះ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ហើយទន្ទឹមនឹងនេះ សូមឱ្យអង្គសន្និបាតរបស់យើងមានដំណើរការប្រកបដោយជោគជ័យ ។

**ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ.............................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី១
## និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា
## ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១ នៅធនាគារជាតិនៃកម្ពុជា

**សូមគោរព :**

- **គណៈអធិបតី**
- **លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

សន្និបាតបូកសរុបលទ្ធផលការងារក្នុងឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជាយើងនៅពេលនេះ បានបញ្ចប់ប្រកបដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយនិងស្និទ្ធស្នាលបំផុត ។ ជារួម ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា សន្និបាតយើងពេលនេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា មិនត្រឹមតែបានបង្ហាញជូនពីស្ថានភាពសេដ្ឋកិច្ចនិងសមិទ្ធផលការងារប៉ុណ្ណោះទេ ថែមទាំងបានចង្អុលបង្ហាញពីទិសដៅការងារ សម្រាប់យកទៅអនុវត្តនៅពេលអនាគតផង ។ ខ្ញុំជឿជាក់ថា សមាជិក-សមាជិកានៃអង្គសន្និបាតយើងពេលនេះ ពិតជាក្តាប់បានពីខ្លឹមសារនៃអង្គសន្និបាត និងយកទិសដៅការងារទៅអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោក លោកស្រី ដែលបានផ្តល់បទអន្តរាគមន៍និងអនុសាសន៍ល្អៗជូនអង្គសន្និបាតយើង ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះសមាជិក-សមាជិកាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងអង្គសន្និបាត និងខិតខំយកចិត្តទុកដាក់ស្តាប់ខ្លឹមសារសំខាន់ ទិសដៅការងារសម្រាប់ឆមាសទី២ និងមានវត្តមានក្នុងអង្គសន្និបាតនេះតាំងពីដើមរហូតដល់ចប់ ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

រយៈពេលពីរថ្ងៃនេះ ខ្ញុំបានកត់សម្គាល់ឃើញថា អង្គសន្និបាតយើងបានស្តាប់ខ្លឹមសារសំខាន់នៃរបាយការណ៍របស់លោកស្រី ងួន សុខា ដែលបានឆ្លុះបញ្ចាំងពីតួនាទីរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការដឹកនាំនយោបាយរូបិយវត្ថុដើម្បីរក្សាស្ថិរភាពថ្លៃ ការត្រួតពិនិត្យគ្រឹះស្ថាន

ធនាគារនិងហិរញ្ញវត្ថុ ការងារគណនេយ្យ ការងារប្រតិបត្តិការជាមួយសាខារាជធានី-ខេត្ត តួនាទីធនាគារកណ្តាលក្នុងការដោះស្រាយវិបត្តិហិរញ្ញវត្ថុអន្តរជាតិ ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ការងារសវនកម្មនិងអធិការកិច្ច និងការងារអគ្គបេឡា ជាដើម ។ ការងារទាំងអស់នេះ ពិតជារួមចំណែកក្នុងការពង្រឹងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា សុខភាពប្រព័ន្ធធនាគារទាំងមូល និងការរក្សាស្ថិរភាពថ្លៃនិងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ឆ្ពោះទៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

នៅឆមាសទី១ ឆ្នាំ២០១១ នេះ កំណើនសេដ្ឋកិច្ចពិភពលោកកំពុងវិវត្តជាវិជ្ជមាន ។ សេដ្ឋកិច្ចអាស៊ីមានមូលដ្ឋានកំណើនរឹងមាំ ពិសេស ប្រទេសចិន ឥណ្ឌា និងឥណ្ឌូណេស៊ី បានឈានមុខគេក្នុងការជំរុញកំណើនសេដ្ឋកិច្ចពិភពលោក ។ ចំពោះកំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០១១ នេះ ត្រូវបានប៉ាន់ស្មានថា នឹងកើនក្នុងកម្រិតពី ៦% ទៅ ៧% ។ កំណើននេះទ្រទ្រង់ដោយភាពអំណោយផលពីវិស័យកសិកម្ម ទេសចរណ៍ កាត់ដេរ និងវិនិយោគផ្ទាល់បរទេស ។ ដើម្បីបន្តចូលរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងគាំទ្រចីរភាពនៃកំណើននេះ ខ្ញុំសូមលើកឡើងនូវមតិខ្លះៗ ដើម្បីឱ្យមន្ត្រីបុគ្គលិកទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្ត ជ្រាបពីអ្វីដែលធនាគារជាតិនៃកម្ពុជាត្រូវធ្វើនាពេលអនាគត ដូចតទៅ ៖

**១/- វិស័យមីក្រូហិរញ្ញវត្ថុ** : ឯកឧត្តម ប៉ាល់ ប៊ុយបុណ្ណាង បានជម្រាបជូនអង្គសន្និបាតរួចហើយ ។ តាមរបាយការណ៍របស់ CGAP បានបញ្ជាក់ថា វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឈានមុខគេ ក្នុងចំណោមប្រទេសដែលមានវិស័យមីក្រូហិរញ្ញវត្ថុចំនួន ៣០ នៅលើពិភពលោក និងបានដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ រាជរដ្ឋាភិបាលកំពុងកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមជារូបវន្ត ។ យើងបានសម្រួលក្របខ័ណ្ឌច្បាប់ ដើម្បីលើកទឹកចិត្តឱ្យគ្រឹះស្ថានទាំងនោះពង្រីកបណ្តាញសេវារបស់ខ្លួនទៅតំបន់ជនបទដាច់ស្រយាល អាចទទួលប្រាក់បញ្ញើពីសាធារណជន និងបង្កើតកម្មវិធីផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការប្រើប្រាស់ឥណទានខ្នាតតូច ។

ដើម្បីបន្តពង្រឹងនិងពង្រីកវិស័យនេះឱ្យរីកចម្រើនថែមទៀត យើងត្រូវរៀបចំឱ្យមានយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុរយៈពេលវែង ដូចជា ១/- បង្កើតការិយាល័យឥណទាន ២/- កែលម្អក្របខ័ណ្ឌច្បាប់និងប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ៣/- បង្កបរិយាកាសប្រកួតប្រជែងលើអត្រាការប្រាក់សេវា និងផលិតផលហិរញ្ញវត្ថុ និង ៤/- ពង្រីកលទ្ធភាពប្រើប្រាស់ឥណទានចំពោះប្រជាជនដែលមានចំណូលទាបនៅតំបន់ជនបទបន្ថែមទៀត។

**២/- ការងារពង្រឹងសុខភាពប្រព័ន្ធធនាគារ :** ស្ថិរភាពនៃប្រព័ន្ធធនាគារ គឺជាការងារអាទិភាពរបស់យើងត្រូវពង្រឹងជាចាំបាច់និងជាប់ជាប្រចាំ ក្នុងខណៈពេលដែលទីផ្សារមូលបត្រនិងទីផ្សារទុនត្រូវបានបង្កើតឡើងនៅពេលថ្មីៗនេះ ។ ការងារនេះ តម្រូវឱ្យមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករយើងពង្រឹងការត្រួតពិនិត្យដល់ទីកន្លែងនិងលើឯកសារជាប់ជាប្រចាំ ដើម្បីជួយពង្រឹងសុខភាពប្រព័ន្ធធនាគារ ជំនឿទុកចិត្តវិនិយោគិន និងការពារផលប្រយោជន៍សាធារណជន សំដៅអភិវឌ្ឍប្រព័ន្ធធនាគារឱ្យប្រព្រឹត្តទៅដោយរលូននិងមានប្រសិទ្ធភាព ។

ដើម្បីអនុវត្តការងារនេះបានសម្រេច យើងត្រូវបន្តលើកកម្ពស់សមត្ថភាពមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករ រៀបចំវិធីសាស្ត្រនៃការត្រួតពិនិត្យដោយផ្អែកលើហានិភ័យ (Risk based) ទស្សនៈអនាគត (Forward-looking) និងការត្រួតពិនិត្យគូបសរុប (Consolidated) បន្ថែមលើយន្តការត្រួតពិនិត្យបច្ចុប្បន្ន ដែលផ្អែកលើមូលដ្ឋានច្បាប់ ។ យើងក៏ត្រូវសហការដើម្បីបង្កើតឱ្យមានការិយាល័យឥណទាន និងបន្តកែលម្អក្របខ័ណ្ឌបទប្បញ្ញត្តិឱ្យស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែលផងដែរ ។

**៣/- ការងារពង្រឹងស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ :** ការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ទាំងផ្នែកបណ្តាញសេវានិងផលិតផលនេះ បានផ្តល់សញ្ញាណពីរ គឺ ១/- ជួយរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម និង ២/- បានបង្ហាញពីសញ្ញាណថ្មីសម្រាប់អាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិករ ត្រូវបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងហានិភ័យទាំងឡាយដែលអាចកើតមានឡើង ដោយសារពិពិតកម្មនៃសេវានិងឧបករណ៍ហិរញ្ញវត្ថុទាំងនេះ ។

ដើម្បីការពារហានិភ័យក្នុងប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ តម្រូវឱ្យអាជ្ញាធររៀបចំនូវក្របខ័ណ្ឌបទប្បញ្ញត្តិ ប្រព័ន្ធប្រកាសអាសន្នជាមុន វិធានការការពារ គ្រប់គ្រងនិងដោះស្រាយវិបត្តិ ស្របតាមគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែល និងបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យនិងបញ្ញត្តិករជាប់ជាប្រចាំ ដើម្បីវាយតម្លៃហានិភ័យ បញ្ហាប្រឈម និងការលើកជាវិធានការសម្រាប់ពង្រឹងស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុ ។ បច្ចុប្បន្ននេះ យើងកំពុងបណ្តុះបណ្តាលក្រុមការងារស្ថិរភាពហិរញ្ញវត្ថុរបស់យើងបណ្តើរ ដើម្បីហាត់រៀនធ្វើការងារនេះបណ្តើរៗ ។

**៤/- ការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច :** លោក ហ៊ុយ ណារី បានជម្រាបជូនអង្គសន្និបាតរួចហើយ ។ ការងារនេះ គឺដើម្បីវាយតម្លៃពីសុវត្ថិភាពនិងសុខភាពធនាគារជាតិនៃកម្ពុជាប្រៀបដូចជាការធ្វើ Medical Checkup ខ្លួនឯង ដើម្បីរកឱ្យឃើញពីចំណុចខ្លាំងនិងចំណុចខ្សោយសម្រាប់កែតម្រូវ ។ កន្លងមក ការងារនេះ មន្ត្រីយើងបានបំពេញបានល្អប្រសើរហើយ ។ មន្ត្រីយើងក៏បានទទួលការបណ្តុះបណ្តាលផ្នែកនេះជាបន្តបន្ទាប់ផងដែរ ទាំងនៅកន្លែងនិងក្រៅប្រទេស ។

ដើម្បីបន្តដំណើរការការងារនេះឱ្យប្រព្រឹត្តទៅដោយរលូន និងមានប្រសិទ្ធភាពថែមទៀត ខ្ញុំសូមស្នើសុំឱ្យបន្តចុះតាមដានការអនុវត្តតាមអនុសាសន៍ដែលបានលើកឡើង និងរៀបចំយន្តការវាយតម្លៃហានិភ័យប្រតិបត្តិការតាមផ្នែក (Targeted re-assessment procedures) និងពង្រឹងការងារអធិការកិច្ច ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្តបន្តទៀត ។ យើងត្រូវរៀបចំផែនការសកម្មភាព និងកំណត់អាទិភាពតាមលំដាប់លំដោយចំពោះការប្រើប្រាស់ប្រព័ន្ធ Flexcube ។ អនុវត្តប្រព័ន្ធនេះដោយរលូន តម្រូវឱ្យមន្ត្រីជំនាញមានស្មារតីតស៊ូព្យាយាម លះបង់ចំពោះការងារ មានភាពស្មោះត្រង់ គោរពវិន័យ និងប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់ចំពោះការងារ ។

**៥/- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ** : ខ្ញុំសូមជម្រាបថា ការងារគ្រប់គ្រងទុនបម្រុងអន្តរជាតិ គឺជាតួនាទីស្នូលរបស់ធនាគារជាតិនៃកម្ពុជា ។ យើងបានពង្រឹងការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ដោយប្រុងប្រយ័ត្ន ដោយផ្អែកលើគោលការណ៍សំខាន់បី គឺ សុវត្ថិភាព សាច់ប្រាក់ងាយស្រួល និងចំណូល ។ បច្ចុប្បន្ន ទុនបម្រុងអន្តរជាតិយើងកើនឡើងជាង ៣ពាន់លានដុល្លារអាមេរិក ស្មើនឹង ៤ខែ នៃការនាំចូល ។ គោលដៅសំខាន់នៃការគ្រប់គ្រងទុនបម្រុងអន្តរជាតិ គឺដើម្បីសម្រួលដល់ការទូទាត់ពាណិជ្ជកម្ម រក្សាស្ថិរភាពថ្លៃ និងបង្កើនជំនឿទុកចិត្តលើរូបិយវត្ថុជាតិ ។ ដូច្នេះ ធនាគារជាតិនៃកម្ពុជាត្រូវរក្សាកម្រិតទុនបម្រុងអន្តរជាតិរបស់ខ្លួនយ៉ាងតិចស្មើនឹង ៣,៥ខែ នៃការនាំចូល ។

**៦/- ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម** : ឯកឧត្តម ផាន់ ហូរ បានជម្រាបជូនអង្គសន្និបាតរួចហើយ ។ ការងារនេះ គឺជាការងារជំនាញផងនិងសហប្រតិបត្តិការផង ទាក់ទងនឹងការរួមចំណែកការពារ ទប់ស្កាត់ និងប្រឆាំងរាល់សកម្មភាពនៃការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅក្នុងប្រព័ន្ធហិរញ្ញវត្ថុ ។ ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ ត្រូវបន្តពង្រឹងនិងពង្រីកយន្តការសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសជាមិត្តក្នុងតំបន់ ដោយសហការជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មជ្ឈមណ្ឌលបណ្តុះបណ្តាលប្រចាំតំបន់ និងធនាគារកណ្តាលបរទេសទាំងក្នុងតំបន់និងពិភពលោក ដើម្បីបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញ ផ្លាស់ប្តូរបទពិសោធន៍គ្នា និងធ្វើការស្រាវជ្រាវអំពីដំណោះស្រាយចំពោះបញ្ហាប្រឈមនានា ដែលកំពុងតែកើតឡើងនៅក្នុងតំបន់និងពិភពលោកនាពេលបច្ចុប្បន្ន ។

ដើម្បីអនុវត្តការងារនេះឱ្យបានជោគជ័យថែមទៀត យើងត្រូវបន្តពង្រឹងការអនុវត្តច្បាប់ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ព្រមទាំងពង្រឹងកិច្ចសហការជាមួយអគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា និងសហគមន៍ជាតិ-អន្តរជាតិបន្ថែមទៀត ។

**៧/- ការពង្រឹងការប្រើប្រាស់ប្រាក់រៀល** : ជាការងារអាទិភាពរបស់យើង ដែលចាំបាច់ត្រូវធ្វើដោយសន្សឹមៗនិងប្រុងប្រយ័ត្ន ។ បញ្ហាដុល្លារូបនីយកម្មជាបញ្ហារួមរបស់យើង ដែលប្រវត្តិសាស្ត្របានបន្សល់ទុកឱ្យយើងទាំងអស់គ្នា ។ ដើម្បីឈានទៅធ្វើបដិដុល្លារូបនីយកម្មចេញពីសេដ្ឋកិច្ចយើងត្រូវរួមគ្នារៀបចំផែនការយុទ្ធសាស្ត្រថ្នាក់ជាតិរយៈពេលវែងមួយ ដើម្បីកំណត់ពីអាទិភាពតាមលំដាប់លំដោយឱ្យបានច្បាស់លាស់ ។

ការកំណត់អាទិភាពមានន័យថា ផ្នែកនយោបាយរូបិយវត្ថុយើងត្រូវមានវិធានការអ្វីខ្លះ? ផ្នែកនយោបាយសារពើពន្ធដែលជាអ្នកគ្រប់គ្រងចំណូលនិងចំណាយថវិកា ត្រូវធ្វើអ្វីខ្លះ? ផ្នែកអប់រំត្រូវធ្វើអ្វីខ្លះដើម្បីជំរុញការផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការប្រើប្រាស់រូបិយវត្ថុ ដើម្បីឱ្យសាធារណជនរត់គំនិតក្នុងការប្រើប្រាស់ប្រាក់រៀល ផ្នែកទេសចរណ៍ដែលជាអ្នកគ្រប់គ្រងសេវាមណ្ឌលកំសាន្តនិងសណ្ឋាគារ ត្រូវធ្វើអ្វីខ្លះ? ផ្នែកពាណិជ្ជកម្ម កសិកម្មនិងមហាផ្ទៃត្រូវធ្វើអ្វីខ្លះ? ។ និយាយឱ្យខ្លី គឺត្រូវមានការចូលរួមពីកម្លាំងសរុប ទើបអាចអនុវត្តផែនការយុទ្ធសាស្ត្រនេះដោយរលូននិងសម្រេចបានជោគជ័យ ។

**៨/- ការងារគណនេយ្យនិងប្រតិបត្តិការ** : លោក អ៊ូ ចាន់តារា និងលោកស្រី គាំ គណ្ណាបានបញ្ជាក់ថា ការងារនេះជាការងារជំនាញទាក់ទងនឹងបច្ចេកទេសកិច្ចចុះបញ្ជិកាហិរញ្ញវត្ថុរបស់ធនាគារជាតិនៃកម្ពុជា ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ឱ្យមានទម្រង់ជារបាយការណ៍ហិរញ្ញវត្ថុរួមមួយ ស្របតាមស្តង់ដារគណនីរបស់ធនាគារជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) ។ ដើម្បីសម្រួលដល់ការងារនេះ យើងបានបំពាក់ប្រព័ន្ធធនាគារស្នូល គឺប្រព័ន្ធ Flexcube ទាំងនៅទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ក្នុងបំណងចែករំលែកព័ត៌មានហិរញ្ញវត្ថុ និងលំហូរការងារឱ្យទាន់គ្នាក្នុងពេលតែមួយ (real time) ចំពោះប្រតិបត្តិការតែមួយដូចគ្នា ។

ដោយសារប្រព័ន្ធនេះថ្មី មានលក្ខណៈវិទ្យាសាស្ត្រទំនើប (computerization) ជាងប្រព័ន្ធចាស់ (manual) ដែលកន្លងមកធ្វើឱ្យយើងជួបការលំបាកដោយអន្លើ ។ ក្នុងការប្រតិបត្តិការងារជាក់ស្តែង យើងតែងជួបការលំបាកខ្លះហើយ ប៉ុន្តែយើងត្រូវតែជម្នះនិងសម្របខ្លួនទៅនឹងការប្រែប្រួលនៃបច្ចេកវិទ្យាថ្មីនិងរៀនប្រើប្រាស់ ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់យើងឱ្យប្រព្រឹត្តទៅដោយរលូន ។

ដើម្បីអនុវត្តការងារនេះបានកាន់តែប្រសើរថែមទៀត ខ្ញុំស្នើសុំឱ្យនាយកដ្ឋានគណនេយ្យនិងនាយកដ្ឋានប្រតិបត្តិការ បន្តបណ្តុះបណ្តាលមន្ត្រីជំនាញនៅសាខារាជធានី-ខេត្តយើង លើផ្នែក ១/- មុខងារប្រព័ន្ធ (Functional) ២/- លំហូរការងារ (Workflows) ៣/- រៀបចំឱ្យមានការណែនាំពីរបៀបប្រើប្រាស់ (User guides) និងជាពិសេស ការប្រើប្រាស់ប្រព័ន្ធទូទាត់ផ្ទាល់ (Direct transfer) ជាលក្ខណៈអន្តរធនាគារ រវាងទីស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ។

**៩/- ការអភិវឌ្ឍប្រព័ន្ធធនាគារស្នូលនិងប្រព័ន្ធជាតិទូទាត់សងប្រាក់** : ប្រព័ន្ធធនាគារស្នូលយើងកំពុងអនុវត្តដោយជោគជ័យ ទាំងនៅទីស្នាក់ការកណ្តាលនិងនៅសាខារាជធានី-ខេត្តមួយចំនួន ។ យើងកំពុងបន្តបំពាក់ប្រព័ន្ធធនាគារស្នូល និងបណ្តុះបណ្តាលមន្រ្តីជំនាញផ្នែកនេះនៅតាមសាខាខេត្តមួយចំនួនបន្ថែមទៀត ។ ចំពោះការងារអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់បច្ចុប្បន្ននេះ ប្រតិបត្តិការទូទាត់សងប្រាក់នេះ ដូចជា មូលប្បទានបត្រ ការបញ្ជាទូទាត់ Credit Card, Debit Card, ATM និងការទូទាត់តាមទូរសព្ទចល័តជាដើម កំពុងមានការរីកចម្រើនយ៉ាងខ្លាំងនៅកម្ពុជា ទាំងផ្នែកបណ្តាញសេវានិងផលិតផលហិរញ្ញវត្ថុ ។ ខណៈពេលដែលទីផ្សារហ៊ុននិងទីផ្សារសញ្ញាប័ណ្ណបានបង្កើតឡើងនេះ នឹងមានឧបករណ៍ហិរញ្ញវត្ថុថ្មីៗថែមទៀត ដូចជា សញ្ញាប័ណ្ណនិងសន្លឹកហ៊ុនជាដើម ដែលជាកម្មវត្ថុនៃការគ្រប់គ្រង ត្រួតពិនិត្យ និងផ្តល់កិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិករ ។ ការរីកចម្រើននៃឧបករណ៍និងសេវាហិរញ្ញវត្ថុនេះ ត្រូវស្ថិតនៅក្រោមច្បាប់ ។

ធនាគារជាតិនៃកម្ពុជាកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធជាតិទូទាត់សងប្រាក់ កសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធជាតិទូទាត់សងប្រាក់ និងបណ្តុះបណ្តាលមន្រ្តីជំនាញ ដើម្បីគ្រប់គ្រងប្រតិបត្តិការនេះ ដោយមានជំនួយបច្ចេកទេសនិងការឧបត្ថម្ភពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ។

**១០/- ការងារប្រតិបត្តិការជាមួយសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត** : អង្គសន្និបាតបានស្តាប់ខ្លឹមសារ និងអនុសាសន៍របស់អង្គសន្និបាតរួចហើយ ។ ដើម្បីបន្តរួមចំណែកអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលដំណាក់កាលទី២ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត យើងបានពង្រីកប្រតិបត្តិការនិងបំពាក់ប្រព័ន្ធធនាគារស្នូលនៅតាមសាខារាជធានី-ខេត្ត ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការបើកគណនី និងគ្រប់គ្រងសេវាគណនីរបស់រដ្ឋ សំដៅជួយសម្រួលចរាចរសាច់ប្រាក់ ប្រតិបត្តិការផ្ទេរសាច់ប្រាក់ ការទូទាត់ពាណិជ្ជកម្ម ការបង់ពន្ធអាករ និងការបើកប្រាក់បៀវត្សជូនមន្រ្តីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទូទាំងប្រទេស ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត ។

នេះគឺជាការងារអាទិភាពរបស់យើង ហើយក៏ជាយន្តការជំរុញការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាលផងដែរ ។ ដូច្នេះ ខ្ញុំសូមស្នើសុំឱ្យសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តត្រូវពង្រឹងការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន ដើម្បីសម្រួលការដាក់ឱ្យចរាចរប្រាក់រៀលឱ្យប្រព្រឹត្តទៅដោយរលូន និងកាន់តែទូលំទូលាយថែមទៀត ។

**១១/- ការងារគ្រប់គ្រងនិងបណ្តុះបណ្តាលមន្រ្តីបុគ្គលិក** : ឯកឧត្តម ស៊ុំ សន្និសិទ្ធ បានអធិប្បាយនិងពន្យល់ពីគោលការណ៍គ្រឹះរបស់គណៈកម្មាធិការទីក្រុងបាសែល ស្តីពីការត្រួតពិនិត្យ

គ្រឹះស្ថានធនាគារ វិធានការប្រុងប្រយ័ត្ននានាក្នុងពេលមានវិបត្តិ និងសភាពការណ៍សេដ្ឋកិច្ចពិភពលោក ។ ទស្សនទានទាំងនេះថ្មី និងមានសារៈសំខាន់ណាស់សម្រាប់មន្ត្រីធនាគារជាតិនៃកម្ពុជា ជាពិសេស សម្រាប់អ្នកត្រួតពិនិត្យ បញ្ញត្តិករ និងប្រតិបត្តិករ ដើម្បីយកទៅអនុវត្តឱ្យស្របតាមស្តង់ដារអន្តរជាតិ ។

ខ្ញុំក៏សូមបញ្ជាក់ថា ធនធានមនុស្សគឺជាកត្តាកំណត់ជោគជ័យនៃការងាររបស់យើងលើគ្រប់ផ្នែក ។ ថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិករបស់យើងបានចូលនិវត្តន៍ជាបណ្តើរៗ ។ ការដាក់ឱ្យចូលនិវត្តន៍នេះ គឺជាកាតព្វកិច្ចតាមផ្លូវច្បាប់ដែលយើងត្រូវតែគោរពទាំងអស់គ្នា ។ ទន្ទឹមនឹងការចូលនិវត្តន៍ យើងត្រូវពិចារណាបណ្តុះបណ្តាលកម្លាំងបន្តវេនជាប់ជាប្រចាំ ដើម្បីបន្តនិរន្តរភាពនិងស្ថិរភាពការងាររបស់យើងនៅពេលអនាគត ។

រយៈកាលកន្លងមក ធនាគារជាតិនៃកម្ពុជាបានបញ្ជូនមន្ត្រីបុគ្គលិកទៅចូលរួមវគ្គសិក្សារយៈពេលវែងនិងខ្លី ទាំងក្នុងនិងក្រៅប្រទេស ក្នុងគោលបំណងលើកកម្ពស់សមត្ថភាព មុខជំនាញឯកទេស ភាសាបរទេស វិន័យការងារ និងស្មារតីទទួលខុសត្រូវចំពោះការងារ ជាពិសេសស្មារតីចេះអភិវឌ្ឍខ្លួនឯងនៅកន្លែងការងារ ។ នេះគឺជារបៀបធ្វើការបណ្តើរ រៀនសូត្របណ្តើរ ។ ការអភិវឌ្ឍធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជាត្រូវធ្វើជាប្រចាំនៅទីកន្លែង ទាំងផ្នែកជំនាញ (IQ) និងផ្នែកគុណធម៌ (EQ) ដើម្បីជ្រើសរើសមន្ត្រីបន្តវេននៅពេលអនាគត ។

បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាកាន់តែមានទំនាក់ទំនងអន្តរជាតិយ៉ាងសកម្ម នៅក្នុងតំបន់និងឆាកអន្តរជាតិ ។ យើងមានដៃគូអភិវឌ្ឍក្នុងតំបន់និងអន្តរជាតិ ដូចជា មជ្ឈមណ្ឌលបណ្តុះបណ្តាល IMF, ADB, WB, មជ្ឈមណ្ឌល SEACEN, ASEAN, ASEAN+3 និងការបណ្តុះបណ្តាលជាលក្ខណៈទ្វេភាគីជាមួយធនាគារកណ្តាលនៅតំបន់អឺរ៉ុប មានធនាគារកណ្តាលបារាំង អាល្លឺម៉ង់ និងលុចហ្សំបួរ និងនៅតំបន់អាស៊ីមានធនាគារកណ្តាលថៃ ម៉ាឡេស៊ី កូរ៉េ វៀតណាម ឡាវ និងម៉ុងហ្គោលីជាដើម ។ ដូច្នេះ សូមឱ្យមន្ត្រីបុគ្គលិកយើងខិតខំសិក្សារៀនសូត្របន្ថែម ដើម្បីដើរឱ្យទាន់សភាពការណ៍រីកចម្រើននៃសេដ្ឋកិច្ច និងមានភាពម្ចាស់ការក្នុងការគ្រប់គ្រងធនាគារជាតិនៃកម្ពុជានិងប្រព័ន្ធធនាគារនៅកម្ពុជា ឱ្យកាន់តែរីកចម្រើនថែមទៀត។

**១២/- ការងារសហប្រតិបត្តិការអន្តរជាតិ :** ការងារនេះមានសារៈសំខាន់ណាស់សម្រាប់ធនាគារជាតិនៃកម្ពុជា ដើម្បី : (១). ពង្រឹងកិច្ចសហប្រតិបត្តិការជាមិត្តភាពជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជា IMF, ADB, WB និងធនាគារកណ្តាលក្នុងតំបន់និងពិភពលោក (២). លើកកម្ពស់កិត្យានុភាពនិងតួនាទីធនាគារជាតិនៃកម្ពុជានៅក្នុងតំបន់និងឆាកអន្តរជាតិ (៣). ជំរុញការធ្វើសមាហរណកម្មវិស័យធនាគារនៅកម្ពុជាចូលទៅក្នុងតំបន់និងពិភពលោក និង (៤). ធ្វើជាវេទិកាថ្នាក់តំបន់សម្រាប់ធ្វើការបណ្តុះបណ្តាលឯកទេសកម្មដល់មន្ត្រីជំនាញ និង

ផ្លាស់ប្តូរយោបល់ពីការងារគ្រប់គ្រងធនាគារកណ្តាល និងការដឹកនាំនយោបាយរូបិយវត្ថុ ឆ្ពោះទៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចជាតិនិងតំបន់ ។

តាមរយៈបទពិសោធន៍នៃការរៀបចំកិច្ចប្រជុំនិងសិក្ខាសាលាអន្តរជាតិកន្លងមក ជាពិសេស ការរៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលនៃក្រុមប្រទេសនិយាយភាសាបារាំង (Francophone) នៅខែឧសភា ឆ្នាំ២០១១ នៅខេត្តសៀមរាប បានធ្វើឱ្យប្រទេសដែលមិនស្គាល់កម្ពុជា បានស្គាល់កម្ពុជា បានឃើញការអភិវឌ្ឍរីកចម្រើននៃសេដ្ឋកិច្ចនិងសង្គមកម្ពុជា និងបានកោតសរសើរចំពោះថ្នាក់ដឹកនាំប្រទេសកម្ពុជា ដែលបានខិតខំស្តារ កសាង និងអភិវឌ្ឍសេដ្ឋកិច្ចឱ្យរីកចម្រើនដូចសព្វថ្ងៃនេះ ។

នៅឆ្នាំ២០១២ ខាងមុខនេះ ប្រទេសកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាននិងទេសាភិបាលធនាគារកណ្តាលអាស៊ានអាស៊ានបូកបី និងកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនទៀត ហើយទន្ទឹមនឹងពេលនោះ ធនាគារជាតិនៃកម្ពុជានឹងត្រូវធ្វើជាម្ចាស់ផ្ទះរៀបចំសន្និបាតនិងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃសមាគមឥណទានកសិកម្មជនបទនៃក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិច ហៅកាត់ថា APRACA ផងដែរ ។ ដើម្បីត្រៀមលក្ខណៈរៀបចំកិច្ចប្រជុំទាំងនេះឱ្យប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ខ្ញុំសូមស្នើសុំឱ្យបណ្តុះបណ្តាលនិងសម្រិតសម្រាំងធនធានមនុស្ស បណ្តុះបណ្តាលមន្ត្រីបង្គោលទទួលបន្ទុកការងារនេះ បង្កើតក្រុមការងារ និងសហការជាមួយក្រសួង-ស្ថាប័នផ្សេងទៀត ។

**១៣/- ការងារអគ្គលេខាធិការនិងការងារសមាគមមន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា** : ឯកឧត្តមថា យ៉ាវ និងលោកស្រី អ៊ុច សុខុម បានអធិប្បាយនិងពន្យល់ច្បាស់លាស់ហើយពីការងារនេះ ។ ការងារអគ្គលេខា គឺជាការងារបច្ចេកទេសហើយត្រូវការទាំងផ្នែកជំនាញនិងស្មារតីទទួលខុសត្រូវ និងតស៊ូអត់ធ្មត់ចំពោះការងារ ។ ដូច្នេះ ដើម្បីបង្កើនប្រសិទ្ធភាពការងារ តម្រូវឱ្យមន្ត្រីទាំងអស់បន្តប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ សីលធម៌ វិន័យការងារ និងគោរពតាមការចាត់តាំងបន្ថែមទៀត ។

ចំពោះការងារសមាគមមន្ត្រីបុគ្គលិកយើង កន្លងមក សមាគមយើងបានបំពេញភារកិច្ចល្អប្រសើរហើយ ។ ខ្ញុំសូមថ្លែងការកោតសរសើរ ។ ដើម្បីពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងក្តាប់បានពីការលំបាករបស់មន្ត្រីបុគ្គលិកយើង ខ្ញុំស្នើសុំឱ្យសមាគមចាត់តាំងឱ្យមានតំណាងបុគ្គលិកសមាគមជាប្រចាំ និងមន្ត្រីដែលបានចូលនិវត្តន៍នៅតាមនាយកដ្ឋាន ឬអង្គភាពរបស់ខ្លួន ដើម្បីងាយស្រួលក្នុងការទំនាក់ទំនង និងរៀបចំកម្មវិធីប្រជុំជីវភាពសមាជិកនៅតាមនាយកដ្ឋាន ឬអង្គភាពរបស់ខ្លួនជាទៀងទាត់ ត្រូវបន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុងជាភាតរភាព និងជួយឧបត្ថម្ភគ្នាទៅវិញទៅមកក្នុងពេលមានការលំបាក ជាពិសេស ត្រូវយកចិត្តទុកដាក់ពីបញ្ហាសុខភាព និងការលំបាកជាក់ស្តែងបន្ថែមទៀត ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីស្នេហា**

ខ្លឹមសារដែលខ្ញុំបានលើកឡើងខាងលើនេះ សុទ្ធតែជាការងាររបស់ធនាគារជាតិនៃកម្ពុជាដែលយើងត្រូវអនុវត្តចំពោះមុខ រយៈពេលមធ្យមនិងវែងនៅពេលអនាគត ដើម្បីពង្រឹងប្រព័ន្ធធនាគារទាំងមូលឱ្យកាន់តែមានសុវត្ថិភាព ប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មខ្ពស់ទៅក្នុងតំបន់ ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាល ។ ខ្ញុំសង្ឃឹមថា លោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់នឹងបន្តការខិតខំប្រឹងប្រែងអនុវត្តទិសដៅភារកិច្ចទាំងឡាយឱ្យសម្រេចបានជោគជ័យ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ សំដៅរួមចំណែកពង្រឹងប្រព័ន្ធធនាគារ និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ឱ្យមានការរីកចម្រើនប្រកបដោយចីរភាព ។

មុននឹងបញ្ចប់ ខ្ញុំសូមផ្តាំផ្ញើនូវមតិមួយចំនួនដូចខាងក្រោម ៖

១/- ត្រូវយកស្មារតីនៃអង្គសន្និបាតរបស់យើងទៅបន្តផ្សព្វផ្សាយ នៅតាមនាយកដ្ឋាន និងអង្គភាពរៀងៗខ្លួន និងអនុវត្តចំពោះការងារប្រចាំថ្ងៃឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

២/- រៀបចំកសាងសារមន្ទីរូបិយវត្ថុជាតិមួយដើម្បីចងក្រងប្រវត្តិនៃការរីកចម្រើននៃប្រព័ន្ធធនាគារ និងរចនាសម្ព័ន្ធរូបិយវត្ថុនៅកម្ពុជា ទុកសម្រាប់សាធារណជនទូទៅសិក្សាស្វែងយល់ និង

៣/- ជំរុញដំណើរការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ឱ្យទៅជា **យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០** របស់រាជរដ្ឋាភិបាលឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងមានលក្ខណៈសមាហរណកម្មជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។

**លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាទីមេត្រី**

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលយ៉ាងច្រើនសម្រាប់ធនាគារជាតិនៃកម្ពុជា និងកសាងប្រព័ន្ធធនាគារឱ្យទទួលបានជំនឿទុកចិត្តពីសាធារណជនជាតិ និងអន្តរជាតិ ។ ដើម្បីសម្រេចបានជោគជ័យថ្មីៗបន្ថែមទៀត ខ្ញុំសូមស្នើសុំឱ្យមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាបន្តស្មារតីរួមសាមគ្គី សហការគ្នាជាប្រពៃណី និងទទួលខុសត្រូវចំពោះការងារ ដើម្បីរួមចំណែកអភិវឌ្ឍប្រព័ន្ធធនាគារឱ្យសម្រេចបាននូវសមិទ្ធផលថ្មីៗថែមទៀតនិងកាន់តែមានប្រសិទ្ធភាព ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គសន្និបាតតាំងពីដើមរហូតដល់ចប់ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបិទអង្គសន្និបាតរបស់យើងចាប់ពីពេលនេះតទៅ ។**

**សូមអរគុណ!**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥-០១០-១៧៣ ប្រ.ក

# ប្រកាស
## ស្តីពី
## ការចេញផ្សាយមូលបត្រអាចជួញដូរបានដោយធនាគារជាតិនៃកម្ពុជា

## ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញប្រកាសលេខ ធ០៥-០៩-២២៩ ប្រ.ក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៩ ស្តីពីការដាក់ឲ្យអនុវត្តកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញដើម្បីធានាដល់ប្រតិបត្តិការអន្តរធនាគារនៅក្នុងទីផ្សាររូបិយវត្ថុ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០

## សម្រេច

### ប្រការ ១.- គោលបំណង

ធនាគារជាតិនៃកម្ពុជាចេញផ្សាយមូលបត្រអាចជួញដូរបានក្នុងគោលបំណងដូចខាងក្រោម ៖

- ជម្រុញការអភិវឌ្ឍទីផ្សាររូបិយវត្ថុ និងការផ្តល់ឥណទានអន្តរធនាគារ ផ្អែកលើមូលដ្ឋានសុវត្ថិភាពដោយមូលបត្រដែលត្រូវបានចេញផ្សាយអាចយកមកប្រើប្រាស់

ជាវត្ថុបញ្ចាំសម្រាប់ប្រតិបត្តិការ ទទួលទិញវិញ(Repo)។

- ផ្តល់ឲ្យអ្នកចូលរួមក្នុងទីផ្សារនូវជម្រើសទ្រព្យសកម្មជាសាច់ប្រាក់ងាយស្រួលមួយទៀតបន្ថែមលើប្រាក់បញ្ញើមានកាលកំណត់នៅធនាគារជាតិនៃកម្ពុជា និងបង្កើតឧបករណ៍បន្ថែមក្នុងគោលដៅជួយគាំទ្រដល់ដំណើរការអនុវត្តគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា ។

នៅពេលមានការស្នើសុំពីអ្នកកាន់ មូលបត្រនឹងអាចត្រូវផ្ទេរទៅឲ្យអ្នកចូលរួមក្នុងទីផ្សារណាមួយផ្សេងទៀតបាន លុះត្រាតែអ្នកទទួលមូលបត្របានបើកគណនីបញ្ញើសាច់ប្រាក់ និងគណនីបញ្ញើមូលបត្រនៅធនាគារជាតិនៃកម្ពុជាដែលមានតួនាទីជាអ្នកថែរក្សាមូលបត្រ ដែលខ្លួនបានចេញផ្សាយ។

## ប្រការ ២ .- លក្ខណៈនិងប្រភេទមូលបត្រដែលបានចេញផ្សាយ

១- មូលបត្រនឹងត្រូវបានចេញផ្សាយតាមសំណើរបស់អ្នកទិញ ដូចជាប្រាក់បញ្ញើមានកាលកំណត់ ដែលដាក់ផ្ញើនៅធនាគារជាតិនៃកម្ពុជាដែរ។ មូលបត្រដែលបានចេញផ្សាយ នឹងទទួលបានអត្រាការប្រាក់ថេរ ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជានៅពេលមានការបញ្ជាទិញ។ ការប្រាក់នឹងត្រូវបានបង្គរតាមមូលដ្ឋានចំនួនថ្ងៃជាក់ស្តែងនៃឆ្នាំនីមួយៗ ។ គូប៉ុង(Coupon) ដែលត្រូវបានគិតបង្គរតាមអាយុកាលនៃមូលបត្រនឹងត្រូវបានទូទាត់សងរួមគ្នាជាមួយតម្លៃចារឹករបស់មូលបត្រនៅកាលវសានទៅឲ្យអ្នកកាន់មូលបត្រ ដូចបានកំណត់ក្នុងប្រការ ៦.២ នៃប្រកាសនេះ។

២- មូលបត្រ ត្រូវបានចេញផ្សាយជាអរូបិយ(Dematerialize) ដូច្នេះត្រូវតែបានដាក់ផ្ញើក្នុងគណនីបញ្ញើមូលបត្រដែលបើកដោយអ្នកទិញនៅធនាគារជាតិនៃកម្ពុជា មុនពេលបញ្ជាទិញ។ គំរូហត្ថលេខាអ្នកមានសិទ្ធិសម្រាប់ការទិញនិងការផ្ទេរមូលបត្រត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា។

៣- ការទិញនឹងត្រូវបានបញ្ជាក់ដោយធនាគារជាតិនៃកម្ពុជា។ ការកាន់កាប់មូលបត្រនេះត្រូវបានបង្ហាញដោយទៀងទាត់ផងដែរនៅក្នុងរបាយការណ៍គណនីមូលបត្រ។

៤- មូលបត្ររបស់ធនាគារជាតិនៃកម្ពុជា នឹងត្រូវបានចេញផ្សាយជារូបិយវត្ថុជាតិនិងជារូបិយប័ណ្ណ។ មូលបត្រទាំងនេះ នឹងត្រូវបានសម្គាល់ដោយលេខមាលាមូលបត្រ និងលេខសម្គាល់អត្តសញ្ញាណនៅក្នុងលេខមាលានេះមានដូចជា តម្លៃចារឹក រូបិយប័ណ្ណ អត្រាការប្រាក់ និងកាលវសាន។

៥- មូលបត្រចារឹកជារូបិយវត្ថុជាតិមានកាលវសានៈ ២សប្តាហ៍ ១ខែ ២ខែ ៣ខែ ៦ខែ ៩ខែ និង១ឆ្នាំ។ មូលបត្រដែលចារឹកជារូបិយប័ណ្ណ មានកាលវសាន ៖ ២សប្តាហ៍ ១ខែ ២ខែ ៣ខែ និង៦ខែ។ ធនាគារជាតិនៃកម្ពុជានឹងកំណត់តម្លៃចារឹកនៃមូលបត្រនៅពេលចេញផ្សាយ ។

## ប្រការ ៣ .- ការថែរក្សា និងការចុះបញ្ជីមូលបត្រ

១- ដូចបានចែងក្នុងប្រការ២ កថាខ័ណ្ឌ២ ខាងលើ មូលបត្រត្រូវចេញផ្សាយជាអរូបិយ (Dematerialize)។ មូលបត្រទាំងនេះ ចាំបាច់ត្រូវដាក់ផ្ញើក្នុងគណនីបញ្ជីមូលបត្រ ដែលបានបើកនៅ ធនាគារជាតិនៃកម្ពុជា។

២- បែបបទនៃការចុះបញ្ជី និងការផ្ទេរកម្មសិទ្ធិមូលបត្រត្រូវធ្វើដោយធនាគារជាតិនៃកម្ពុជា។

## ប្រការ ៤ .- ម្ចាស់កម្មសិទ្ធិលើមូលបត្រ

១- កម្មសិទ្ធិលើមូលបត្រអរូបិយ(Dematerialize) ត្រូវបានបញ្ជាក់ជាភស្តុតាងដោយការធ្វើលេខាចារឹកដោយទៀងទាត់នៅក្នុងគណនីបញ្ជីមូលបត្រ ដែលបានបើកនៅធនាគារ-ជាតិនៃកម្ពុជា ដែលជាអ្នកចេញផ្សាយ និងជាអ្នកថែរក្សាមូលបត្រ។

ដូច្នេះ រាល់ការផ្លាស់ប្តូរកម្មសិទ្ធិចាំបាច់ត្រូវជូនដំណឹងមកធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីបញ្ជាក់លើការផ្ទេរកម្មសិទ្ធិនេះ ឲ្យទៅអ្នកលក់និងអ្នកទិញមូលបត្រ។

២- ការបញ្ជាក់របស់ធនាគារជាតិនៃកម្ពុជា ទៅឲ្យអ្នកទិញតែម្ខាងមិនមែននឹងមិនអាចចាត់ទុកជាប័ណ្ណសម្គាល់កម្មសិទ្ធិអាចជួញដូរបាននោះទេ និងដូចនេះអ្នកចូលរួមក្នុងទីផ្សារមិនអាចធ្វើបិដ្ឋិលេខដើម្បីផ្ទេរកម្មសិទ្ធិមូលបត្រទាំងនោះបានឡើយ។

ការផ្ទេរកម្មសិទ្ធិនេះ អាចធ្វើឡើងស្របច្បាប់បានលុះត្រាតែធនាគារជាតិនៃកម្ពុជាទទួលបានបញ្ជាពីភាគីទាំងពីរ ក្នុងការធ្វើប្រតិបត្តិការទិញ-លក់ផ្តាច់ ឬប្រតិបត្តិការដាក់វត្ថុធានា ជាពិសេសក្នុងទម្រង់ជាប្រតិបត្តិការទទួលទិញវិញ ឬដាក់បញ្ចាំជាវត្ថុធានាតែប៉ុណ្ណោះ។

## ប្រការ ៥ .- ប្រតិបត្តិការទទួលទិញវិញ(Repo)

១- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានទទួលយកសម្រាប់ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ។ ក៏ប៉ុន្តែ ដើម្បីធានាសុវត្ថិភាពតាមកិច្ចសន្យា និងតាមផ្លូវច្បាប់ សម្រាប់ប្រតិបត្តិការទាំងនោះ អ្នកចូលរួមក្នុងទីផ្សារទាំងឡាយត្រូវតែចុះហត្ថលេខាលើកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញរបស់ធនាគារជាតិនៃកម្ពុជា ។

២- ជាគោលការណ៍ ប្រតិបត្តិការទទួលទិញវិញនៅក្នុងទីផ្សាររូបិយវត្ថុ ត្រូវរួមបញ្ចូលនូវដំណាក់កាលពេញលេញដែលអនុវត្តដោយភាគីទាំងពីរ ក្នុងការបញ្ជាមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិមូលបត្រ ដែលបានលក់ ក្រោមកិច្ចសន្យាទទួលទិញវិញ។

៣- ចំពោះប្រតិបត្តិការដែលមានរយៈពេលខ្លី ភាគីនៃកិច្ចសន្យាអាចមិនចាំបាច់បញ្ជាមកធនាគារជាតិនៃកម្ពុជា ដើម្បីធ្វើការផ្ទេរកម្មសិទ្ធិមូលបត្រដែលបានលក់ក្រោមកិច្ច

សន្យាទទួលទិញវិញនោះឡើយ។ ក្នុងករណីនេះ អ្នកលក់មូលបត្រ (ភាគីខ្ចីប្រាក់) ត្រូវតែដើរតួជាអ្នកថែរក្សាមូលបត្របន្ទាប់ឲ្យអ្នកទិញមូលបត្រ(ភាគីឲ្យខ្ចីប្រាក់)និងចុះបញ្ជិកាគណនេយ្យជាបន្តបន្ទាប់ដើម្បីជាភស្តុតាងនៃការផ្ទេរកម្មសិទ្ធិ។

៨- ប្រតិបត្តិការទទួលទិញវិញអាចធ្វើបានដោយប្រើរូបិយប័ណ្ណខុសៗគ្នា យោងតាមកិច្ចសន្យាទ្វេភាគីរបស់ភាគីទាំងពីរ។ ក្នុងករណីនេះ ភាគីខ្ចីប្រាក់ជាអ្នក ទទួលរង ហានិភ័យនៃអត្រាប្តូរប្រាក់ (អ្នកលក់មូលបត្រសន្យាថានឹងទិញមូលបត្រវិញតាមតម្លៃដែលបានព្រមព្រៀងទុកជាមុន)។ លើសពីនេះ ភាគីដែលទទួលរងហានិភ័យនៃអត្រាប្តូរប្រាក់នឹងត្រូវបានបង្ហាញ និងទទួលបន្ថែមម៉ាជីនខលជាសាច់ប្រាក់ (Cash Margin Calls) ប្រសិនបើចាំបាច់។

## ប្រការ ៦ .- ការបញ្ជាក់ និងការបញ្ជាផ្ទេរ

១- ការបញ្ជាក់លើការទិញ ដោយធនាគារជាតិនៃកម្ពុជា មិនរួមបញ្ចូលកម្មសិទ្ធិភាពលើមូលបត្រដែលបានទិញនោះទេ។ ដូច្នេះការបញ្ជាក់នេះ មិនអាចចាត់ទុកជាវិញ្ញាបនបត្រដែលអាចធ្វើបិដ្ឋិលេខដោយអ្នកចូលរួមទីផ្សារ ព្រោះថាការធ្វើបដ្ឋិលេខនោះនឹងមិនរួមបញ្ចូលសិទ្ធិកាន់កាប់លើមូលបត្រនោះឡើយ។

២- មូលបត្រដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ជាមូលបត្រអរូបិយ (Dematerialize) ភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រគឺជាលទ្ធផលនៃការធ្វើលេខាចារឹកដោយទៀងទាត់លើមូលបត្រទាំងនោះនៅក្នុងគណនីបញ្ញើមូលបត្រ ដែលបានបើកនៅធនាគារជាតិនៃកម្ពុជា។ នៅកាលវសាន តម្លៃចារឹកនៃមូលបត្រ និងគូប៉ុងដែលបានបង្គរត្រូវបានផ្ទេរដោយស្វ័យប្រវត្តិ ចូលក្នុងគណនីចរន្តនៅធនាគារជាតិនៃកម្ពុជាដែលពាក់ព័ន្ធជាមួយគណនីបញ្ញើមូលបត្រនោះ។ ក៏ប៉ុន្តែ ក្នុងករណីដែលអ្នកចូលរួមទីផ្សារមានបំណងវិនិយោគឡើងវិញនូវចំនួនប្រាក់ទាំងអស់ ឬមួយផ្នែកនៃចំនួនប្រាក់ដែលបានទទួលអ្នកចូលរួមនោះត្រូវផ្តល់បញ្ជាទៅធនាគារជាតិនៃកម្ពុជាឲ្យបានមុនកាលវសានចំនួនពីរថ្ងៃនៃថ្ងៃធ្វើការ។

៣- នៅពេលចេញផ្សាយមូលបត្រ ក្រោយពីទទួលបានបញ្ជាទិញជាលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខាដោយអ្នកទទួលសិទ្ធិ ធនាគារជាតិនៃកម្ពុជានឹងចុះឥណពន្ធក្នុងគណនីចរន្តដោយស្វ័យប្រវត្តិនិងចុះឥណទានគណនីបញ្ញើមូលបត្រដែលពាក់ព័ន្ធរបស់អ្នកកាន់មូលបត្រ នៅថ្ងៃប្រសិទ្ធិភាពដែលកំណត់នៅលើបញ្ជាទិញ។ អ្នកទិញ និងអ្នកចូលរួមដេញថ្លៃត្រូវធានាថា មានសមតុល្យសាច់ប្រាក់គ្រប់គ្រាន់នៅ ក្នុងគណនីដើម្បីទូទាត់សងថ្លៃមូលបត្រដែលបានទិញ ឬដេញថ្លៃបាន។

៤- ដើម្បីអនុវត្តការផ្ទេរកម្មសិទ្ធិមូលបត្រដែលត្រូវបានលក់និងទិញយកវិញ តាមរយៈប្រតិបត្តិការទទួលទិញវិញ ធនាគារជាតិនៃកម្ពុជាតម្រូវឲ្យភាគីទាំងពីរបញ្ជាក់លើបញ្ជាជា

លាយលក្ខណ៍អក្សរចំនួនពីរដោយឡែកពីគ្នាទាក់ទងនឹងប្រតិបត្តិការទទួលទិញវិញនោះ។ ដើម្បីជៀសវាងការយឺតយ៉ាវ ភាគីទាំងពីរត្រូវធ្វើការបញ្ជាក់ឲ្យគ្នាទៅវិញទៅមកនូវបញ្ជារបស់ខ្លួន ហើយត្រូវធានាថា ការបញ្ជាក់ទាំងនោះមានខ្លឹមសារស្របគ្នាទាំងស្រុង។

៥- ក្នុងដំណើរការនៃប្រតិបត្តិការទទួលទិញវិញ ទោះបីភាគីទាំងពីរយល់ព្រមទូទាត់ម៉ាជីនជាសាច់ប្រាក់ ឬដាក់បន្ថែមម៉ាជីនជាមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរចំនួនពីរ ដែលមានខ្លឹមសារស្របគ្នាទៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមបទប្បញ្ញត្តិ ដែលបានចែងក្នុងកថាខណ្ឌទី ៤ ខាងលើ។

៦- ទោះបីជាភាគីទាំងពីរសម្រេចចិត្ត ទិញលក់ផ្តាច់ជាមួយគ្នានូវមូលបត្រក៏ដោយ ក៏ភាគីទាំងពីរត្រូវបញ្ជាទៅធនាគារជាតិនៃកម្ពុជា ទាំងការផ្ទេរមូលបត្រដែលបានទិញ ឬលក់នោះផង និងការទូទាត់សាច់ប្រាក់ ដោយបញ្ជាក់អំពីថ្ងៃប្រសិទ្ធភាព និងចំនួនប្រាក់ដែលត្រូវបានទូទាត់សងផងដែរ។ ចរិត លក្ខណៈនៃមូលបត្រដែលត្រូវបានទិញ ឬលក់ ត្រូវតែបានបញ្ជាក់លើបញ្ជាជាលាយលក្ខណ៍អក្សរឲ្យច្បាស់លាស់ ដោយភាគីទាំងពីរនៅលើប្រតិបត្តិការដែលបានធ្វើ។

## ប្រការ ៧ .- ឥណទានអូវើណាយដែលមានការធានា និង ឌីសខោនវីនដូ

(Overnight Secured Facilities and Discount Window)

១- ក្រោមលក្ខខណ្ឌដែលនឹងត្រូវមានចែងក្នុងប្រកាសដោយឡែករបស់ធនាគារជាតិនៃកម្ពុជា មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា អាចត្រូវបានប្រើប្រាស់ជាវត្ថុធានាសម្រាប់ការផ្តល់ឥណទានអូវើណាយ(Overnight) ក្នុងគោលបំណងផ្តល់ភាពទន់ភ្លន់ឲ្យអ្នកចូលរួមទីផ្សារក្នុងការបំពេញសមតុល្យផាត់ទាត់អវិជ្ជមានរបស់ខ្លួនរយៈពេលមួយថ្ងៃ។ ឥណទាននេះ មិនត្រូវបានចាត់ទុកជាប្រភពទុនអចិន្ត្រៃយ៍របស់សមាជិកសភាផាត់ទាត់ឡើយ ហើយធនាគារជាតិនៃកម្ពុជានឹងផ្តល់ឥណទាននេះតាមអត្រាការប្រាក់ផាកពិន័យ។

២- ឥណទានអូវើណាយ (Overnight) ត្រូវបានធានាដោយមូលបត្រកាន់កាប់ដោយសមាជិកសភាផាត់ទាត់តាមតម្លៃចារឹកសមមូល ឬខ្ពស់ជាងកំរិតឥណទាន។ ធនាគារជាតិនៃកម្ពុជា នឹងផ្ទេរកម្មសិទ្ធិវត្ថុធានា ក្រោយពីបញ្ជាក់អំពីការផ្តល់ឥណទានអូវើណាយ(Overnight) នោះដល់អគ្គាគាហក។ ធនាគារជាតិនៃកម្ពុជានឹងសងមូលបត្រត្រឡប់វិញនៅថ្ងៃបន្ទាប់ក្រោយពីគណនីផាត់ទាត់មានសមតុល្យវិជ្ជមានឡើងវិញ។

៣- មូលបត្រដែលកាន់កាប់ដោយអ្នកចូលរួមទីផ្សារអាចប្រើប្រាស់សម្រាប់បំពេញតម្រូវការ សាច់ប្រាក់ងាយស្រួលបណ្តោះអាសន្ននិងរយៈពេលខ្លី។ ប្រតិបត្តិការនេះត្រូវតែមានការយល់ព្រមជាមុនពីធនាគារជាតិនៃកម្ពុជា និងត្រូវបានផ្តល់សម្រាប់ចន្លោះពេលពី ២ថ្ងៃ

រហូតដល់ ២សប្តាហ៍នៃថ្ងៃធ្វើការ។ ការចូលទៅប្រើឥណទានអប្បហារ នឹងមិនត្រូវបានជំនួសដោយឥណទានវិបារូបន៍ឡើយ ដោយឥណទានទាំងពីរនេះមានលក្ខណៈខុសគ្នា។ ការធ្វើប្រតិបត្តិការអប្បហារជាមួយធនាគារជាតិនៃកម្ពុជានឹងត្រូវស្ថិតនៅក្រោមលក្ខខណ្ឌ ដែលថាមូលបត្រនោះមានតម្លៃអាចទទួលយកបាន (អាចជួញដូរបាន)។ បញ្ជីមូលបត្រដែលអាចទទួលយកបានសម្រាប់ធ្វើប្រតិបត្តិការអប្បហារ និងអត្រាអប្បហារ ត្រូវបានធ្វើបច្ចុប្បន្នកម្ម និងចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា។

៤- ប្រតិបត្តិការដែលដំណើរការក្នុងឱសខោនវីនដូ នឹងត្រូវគាំទ្រដោយកិច្ចសន្យាមេសម្រាប់ប្រតិបត្តិការទទួលទិញវិញ ដែលចុះហត្ថលេខាដោយធនាគារជាតិនៃកម្ពុជា និងអត្ថាគាហកមូលបត្រ។ ធនាគារជាតិនៃកម្ពុជានឹងផ្ទេរមូលបត្រ ដែលត្រូវបានជ្រើសរើសនិងព្រមទទួលយក នៅថ្ងៃចាប់ផ្តើម និងនៅកាលវសាននៃប្រតិបត្តិការ។

## ប្រការ ៨ .- ប្រតិបត្តិការទីផ្សារចំហរ និងការដេញថ្លៃ

១- ទន្ទឹមនឹងការបញ្ជាទិញជាធម្មតានៃមូលបត្រចេញផ្សាយដោយធនាគារជាតិនៃកម្ពុជាតាមអត្រាដែលបានកំណត់ ធនាគារជាតិនៃកម្ពុជាក៏អាចរៀបចំដាក់ឲ្យដេញថ្លៃមូលបត្រដោយការជូនដំណឹងជាមុនតាមចំនួនដែលបានកំណត់ទៅឲ្យអ្នកចូលរួមដេញថ្លៃ។

២- ការដេញថ្លៃនេះ នឹងត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តឲ្យមានប្រសិទ្ធភាពនូវប្រតិបត្តិការទីផ្សារចំហរ និងធ្វើឲ្យសម្រេចគោលដៅនៃគោលនយោបាយរូបិយវត្ថុនិងប្តូរប្រាក់របស់ធនាគារជាតិនៃកម្ពុជា។

## ប្រការ ៩ .- អ្នកចូលរួមក្នុងការដេញថ្លៃ និងការអនុវត្តប្រតិបត្តិការទីផ្សារចំហរ

១- ការរៀបចំ និងលក្ខខណ្ឌផ្សេងៗសម្រាប់ការចូលរួមដេញថ្លៃ នឹងត្រូវបានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងដោយឡែកៗពីគ្នា រៀងរាល់ការដេញថ្លៃនីមួយៗ ដែលនឹងប្រព្រឹត្តទៅតាមការផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជា ដើម្បីអញ្ជើញអ្នកចូលរួមដូចមានចែងក្នុងកថាខណ្ឌ ២ ខាងក្រោមឲ្យចូលរួមដេញថ្លៃ។

២- ការដេញថ្លៃ នឹងត្រូវអនុញ្ញាតចំពោះអ្នកចូលរួមក្នុងទីផ្សាររូបិយវត្ថុជាប្រក្រតី។ ក៏ប៉ុន្តែ ធនាគារជាតិនៃកម្ពុជាអាចអនុញ្ញាតឲ្យអ្នកផ្សេងទៀតចូលរួមដេញថ្លៃ ដូចជា អាជីវករប្តូរប្រាក់ ក្រុមហ៊ុនមូលបត្រ និងស្ថាប័នហិរញ្ញវត្ថុដទៃទៀតជាដើម។ អ្នកដែលត្រូវបានអញ្ជើញឲ្យចូលរួមដេញថ្លៃ ត្រូវមានបញ្ជាក់នៅក្នុងសេចក្តីជូន ដំណឹងស្តីពីការដេញថ្លៃនីមួយៗដែលរៀបចំដោយធនាគារជាតិនៃកម្ពុជារួមជាមួយនិងព័ត៌មានផ្សេងៗទៀតដែលចាំបាច់ ឬសមស្របសំរាប់ការរៀបចំខ្លួន និងការដាក់ពាក្យសុំចូលដេញថ្លៃ។

**ប្រការ ១០ .-  ការប្រើប្រាស់មូលបត្ររបស់ធនាគារជាតិនៃកម្ពុជាសម្រាប់ជាវត្ថុធានាក្នុងប្រតិបត្តិការទូទាត់ដុលតាមពេលវេលាពិត** (RTGS)

មូលបត្រដែលបានចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា នឹងត្រូវបានទទួលយកជាវត្ថុធានា ដើម្បីធានាដំណើរការនៃប្រព័ន្ធទូទាត់ដុលតាមពេលវេលាពិត។ បែបបទបង្កើតឲ្យមានជាប្រក្រតីនូវវត្ថុធានានោះ នឹងត្រូវបានចែងនៅក្នុងបទបញ្ជាស្ដីពីប្រតិបត្តិការប្រព័ន្ធទូទាត់ដុលតាមពេលវេលាពិត។

**ប្រការ ១១ .-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ១២ .-**

ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០

**ជា ចាន់តូ**

<u>កន្លែងទទួល:</u>

- ដូចប្រការ ១១
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន:</u>

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្ដីការគណៈរដ្ឋមន្ត្រី
  **"ដើម្បីជូនជ្រាបជាព័ត៌មាន"**
- នាយកដ្ឋានរដ្ឋបាលទីស្ដីការគណៈរដ្ឋមន្ត្រី
  **"ដើម្បីចុះផ្សាយក្នុងរាជកិច្ច"**

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number: B5.010.183 Pro.Kor

Unofficial Translation

# PRAKAS
# On
# The Issuance of Tradable Securities by the National Bank of Cambodia

The Governor of the National Bank of Cambodia

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996, promulgating the Law on the Organization and Functioning of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 of December 29, 2006, promulgating the Law on the amendment articles 14 and 57 of the Law on the Organization and Functioning of the National Bank of Cambodia;
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008, on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- With reference to the Prakas No. Thor 5-09-229 Pro.Kor dated 19 October 2009 on the Implementation of Repo Master Agreement for Secured Interbank Transaction in the Money Market
- Pursuant to the recommendation made by National Bank of Cambodia management during the 14 September, 2010 meeting.

## DECIDE

### Article 1.- Objectives

The National Bank of Cambodia will issue tradable securities with the following objectives:

- Promoting the development of a money market and interbank lending on secured bases, where the securities issued could serve as collateral for repo-transactions;
- Providing the market participants with alternative liquidity reserve assets supplementing the fixed deposits held with the Central Bank; and
- Establishing additional instruments aimed at supporting the implementation of the Central Bank's monetary and foreign exchange policies.

At holders' request, such securities can be transferred to any other market participant, provided such participant has been opened a securities and a cash account with the NBC, acting as a custodian for its own securities issued.

**Article 2.- Nature and denomination of securities issued**

1. The securities will be issued at the subscribers' request as an alternative to fixed term deposits with the National Bank of Cambodia. Such securities will bear interest at a fixed rate determined by the NBC at subscription. Interest will be accrued base on actual number of days in each year. The coupons accrued over the life of the securities will be paid with the nominal to the regular holder of securities at redemption date (maturity) under the provisions set forth in article 6.2, below.
2. The securities are dematerialized and therefore need to be deposited in a custodian account to be opened with the National Bank of Cambodia by the subscribers prior to subscription. The Authorized signatures for transferring and subscribing such securities shall be deposited with the National Bank of Cambodia.
3. Subscriptions will be confirmed by confirmations to be issued by the National Bank of Cambodia. Holdings of such securities will also be regularly reflected by securities accounts statements.
4. The National Bank of Cambodia securities will be issued in both, KHR (Khmer Riels) and USD (US dollars). Such securities shall be identified by securities' serial number and identification number within the series, nominal amount, currency, interest rate and maturity.
5. The Securities issued in domestic currency (KHR) will be available for following maturities: 2 weeks, 1 month, 2 months, 3 months, 6 months, 9 months and 1 year. The securities issued in US dollars (USD) will be available for following maturities: 2 weeks, 1 month, 2 months, 3 months and 6 months. The NBC will determine the denominations of the securities on the issuing date.

**Article 3.- Custody and registration of the securities**

1. As mentioned earlier in Article 2, paragraph 2, the securities will be dematerialized. They need to be deposited in a nominative custodian account opened with the National Bank of Cambodia.
2. Registration formalities and ownership transfers will be performed by the National Bank of Cambodia.

**Article 4.- Ownership of securities**

1. The ownership of dematerialized securities is evidenced by regular inscription on the owner's custodian account held with the National Bank of Cambodia, acting as both issuer and custodian.

   Any change in ownership needs therefore to be notified to the National Bank of Cambodia that will confirm the transfer to both, seller and purchaser of the securities.
2. The sole confirmation issued by the National Bank of Cambodia to the purchaser shall not and cannot be considered as a tradable property title and shall therefore not be endorsed by market participants for the purposes of property transfer of the transacted securities.

   Such ownership transfer can only be legally performed by the National Bank of Cambodia at reception of according instructions issued by both parties to a straight forward sell-purchase transaction or to a collateralized transaction, notably in the form of a repo or a pledge as collateral.

## Article 5.- Repo-transactions

1. Securities issued by the National Bank of Cambodia are eligible to repo transactions transacted in the Money Market. However, to ensure for legal and contractual security of such transactions, market participants are required to sign on the National Bank of Cambodia Repo Master Agreement.
2. Repo transactions transacted in the money market shall, in principle, involve that adequate steps be taken by both parties instructing the National Bank of Cambodia to operate the ownership transfer of the securities sold under repurchase agreement.
3. For very short period of times, parties to a repo transaction might not be willing to instruct the National Bank of Cambodia to operate the transfer of ownership of the securities sold under repurchase agreement. In this case, the securities seller (cash borrowing party) shall act as a sub-custodian on behalf of the securities purchaser (cash lending party) and account for such securities subsequently in order to evidence the ownership transfer.
4. Repo-transactions might be transacted in different currencies according to the parties' bilateral agreements. In this case, the currency risk shall be supported by the cash borrowing party (securities' seller committed to repurchase at a pre-agreed price). In addition, the counterparty risk exposures involved by currency rate moves shall be monitored and, where applicable, covered by cash margin calls.

## Article 6.- Confirmations and Transfer

1. Purchase confirmations issued by the National Bank of Cambodia do not incorporate the ownership of the securities purchased. Therefore, such confirmations shall not be considered as certificates that could be endorsed by market participants since such endorsement will not incorporate the possession right about the securities.
2. The securities issued by the National Bank of Cambodia being dematerialized, the ownership results from the regular inscription of such securities in a custodian accounts held with the National Bank of Cambodia. At maturity date, the nominal amount invested as well as the accrued coupon will be automatically transferred to the current account held with the National Bank of Cambodia that is associated to the custodian account. However, should a market participant intend to reinvest all or part of the redemption amount, the National Bank of Cambodia will have to be instructed consequently two working days before maturity date.
3. At issuance of the securities, the National Bank of Cambodia will, at reception of written purchase confirmations signed on by duly authorized signatures, automatically debit the current account associated to the custodian account of the holder in which the securities will be deposited, at value date specified on the instruction. Purchasers and participants in the auctions shall ensure that they hold sufficient balances in their accounts to pay for the securities purchased or attributed to their bids.
4. To perform the transfer of ownership of securities sold and repurchased by means of repo transactions, the National Bank of Cambodia will require two regular instruction confirmations in writing issued by both parties to such repo transactions. To prevent from undue delays, the parties are required to confirm their instructions among themselves and to ensure that both confirmations are fully accordant.
5. In the course of any repo transactions should the parties agree to settle cash margins or to deliver additional securities margins the parties are required to issue to the Central bank two accordant instruction confirmations in compliance with the provisions set forth in paragraph 4, above.

6. Should two parties decide to perform a straight forward sale and purchase of securities issued by the National Bank of Cambodia they shall instruct both the Central Bank to perform the transfer of the sold / purchased securities and to settle the cash payment by specifying value date and transaction price. The characteristics of the securities sold / purchased shall be clearly specified on the instructions forwarded in writing by both parties to such transaction.

**Article 7.- Overnight secured facilities and Discount window**

1. Under conditions to be determined by Prakas to be issued by the National Bank of Cambodia, the securities issued will be eligible to secured overnight facilities aimed providing the market participants with some flexibility to cover their negative clearing balances. Such overnight facilities shall not be considered as a regular funding source by clearing members and shall be granted at a penalty rate published by the National Bank of Cambodia.
2. Overnight facilities shall be secured by an equivalent or higher nominal amount in securities regularly owned by the clearing participant. The transfer of ownership of the collateral will be performed after confirmation of such facilities to the beneficiaries and at the initiative of the National bank of Cambodia. The restitution of the securities will also be performed next day at the Central Bank's initiative after reconstitution of a positive cash balance on the clearing account.
3. For temporary and short term liquidity needs, the securities held by market participants will be eligible to the liquidity window. Such transactions shall be pre-approved by the National Bank of Cambodia and shall be granted for periods of time ranging between two working days and two weeks. Access to the Discount Window shall not substitute for overdraft facilities that are of different nature. The access to the central bank discount operations will be conditioned by the effective availability of eligible securities. The list of eligible securities for discount will be updated and published by the National Bank of Cambodia as well as the applicable discount rates.
4. The transactions performed within the Discount Window shall be supported by the signature of a Repo Master Agreement between the National Bank of Cambodia and the beneficiary. The designated and approved upon securities will be transferred at the initiative of the National Bank of Cambodia at both, initiation and maturity of the transactions.

**Article 8.- Open Market Operations and Auctions**

1. Alongside with the regular subscriptions of securities issued by the National Bank of Cambodia at the applicable rates, the latter might organize auctions whereby a pre-defined amount of securities targets would be auctioned to the qualifying bids made by the participants to the process.
2. Such auctions will be organized to support the effective implementation of the National Bank of Cambodia's open market operations, the fine tuning and the achievement of its monetary and foreign exchange policies targets.

**Article 9.- Participants to the Auctions and Implementation of Open Market Operations**

1. The organization and conditions for participating in the auctions organized by the National Bank of Cambodia will be specified in circulars specific to each auction to take place at its initiative with the aim of inviting the participants referred in paragraph 2 below to submit their bids.

2. The auctions will be opened to regular money market participants. However, at the National Bank of Cambodia's discretion, such auctions might be opened to other participants, such as foreign-exchange auctions' participants, securities firms and other financial institutions. The participants invited to the auctions shall be specified in the invitation circulars addressing each of the auctions organized by the NBC, alongside with other information deemed necessary or appropriate for the preparation and submission of the bids.

**Article 10.- Eligibility of NBC Securities as a collateral for the Real Time Gross Settlements (RTGS) System**

The securities issued by the National Bank of Cambodia will be eligible as collateral in order to secure the processing of the RGTS System. The modalities for the regular constitution of such collateral will be addressed by a Prakas on the operations of the RTGS System.

**Article 11.-**

The General Director, the General Secretariat, the General Cashier, the General Inspection, all Departments of the National Bank of Cambodia and all Banking and Financial Institutions under the National Bank of Cambodia's supervisory authority shall strictly implement this Prakas.

**Article 12.-**

The present Prakas shall take effect from its date of signature.

**Phnom Penh, 15/10/2010**
**Governor**
**CHEA CHANTO**

cc:

- The Members of the Board of Directors
- The parties concerned as stated in Article 11
- File
- CM "for info."
- Administration Department of CM
"for publication in the National Gazette"

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧ ០១១ ០៥៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងសំណើរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
- យោងសេចក្តីសម្រេចនៃអង្គប្រជុំថ្នាក់ដឹកនាំ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០១១

## សម្រេច

**ប្រការ ១.-**

គ្រប់គ្រឹះស្ថានធនាគារតទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវប្រតិបត្តិតាមជាអចិន្ត្រៃយ៍នូវរាល់កាតព្វកិច្ចដែលកំណត់ដោយបទបញ្ញាជាធរមាន ។ ការប្រតិបត្តិតាមជាអចិន្ត្រៃយ៍នេះអាចនឹងសម្រេចបានតាមរយៈគោលនយោបាយច្បាស់លាស់ នីតិវិធីនិងដំណើរការសមស្រប និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងត្រួតពិនិត្យហានិភ័យ។ ការគួបផ្សំគ្នានៃចំណុចខ្សោយចម្បងៗ រួមជាមួយការទទួលយកហានិភ័យហិរញ្ញវត្ថុ អាចនាំឲ្យមានទម្រង់ហានិភ័យពីការប្រើប្រាស់ផ្នែកទ្រព្យអកម្មដែលជាបំណុល និងកំណើនខ្លាំងនៃភាពងាយរងគ្រោះ ព្រមទាំងធ្វើឲ្យ

អន្តរាយដល់សមត្ថភាពទប់ទល់នឹងការវិវត្តអវិជ្ជមានដែលអាចប៉ាន់ប្រមាណជាមុន ។ ដើម្បីវាយតម្លៃទម្រង់ហានិភ័យបានពេញលេញនៅកម្រិតគ្រឹះស្ថានធនាគារ និងបើចាំបាច់នៅកម្រិតគួបសរុប ធនាគារជាតិនៃកម្ពុជានឹងអនុវត្តការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យ និងទស្សនៈអនាគត ក្នុងគោលបំណងប៉ាន់ប្រមាណជាមុននូវការវិវត្តអវិជ្ជមានជាសក្តានុពល និងដោះស្រាយទាន់ពេលវេលា ដោយដាក់ចេញអធិបញ្ញាសមស្រប ដើម្បីអនុវត្តសកម្មភាពកែតម្រូវចាំបាច់ ប្រកបដោយការទទួលខុសត្រូវ និងប្រសិទ្ធភាព។

**ប្រការ ២.-**

ការត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគត សំដៅដល់ដំណើរការតាមដានត្រួតពិនិត្យអចិន្ត្រៃយ៍លើមូលដ្ឋាននៃការវាយតម្លៃទម្រង់ហានិភ័យ ការប៉ាន់ប្រមាណនិងការធ្វើស្ត្រេសតេស្ត (Stress-testing) ផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យ ដើម្បីកំណត់អត្តសញ្ញាណកត្តានៃភាពងាយរងគ្រោះនិងភាពចុះខ្សោយរបស់គ្រឹះស្ថានឬក្រុមគ្រឹះស្ថានដែលរងការត្រួតពិនិត្យ និងប៉ាន់ប្រមាណអំពីបញ្ហានិងកង្វល់នៃការត្រួត-ពិនិត្យឲ្យបានទាន់ពេលវេលា សំដៅដោះស្រាយជាបន្ទាន់ ទប់ស្កាត់ស្ថានភាពហិរញ្ញវត្ថុចុះខ្សោយជាលំដាប់ និងពង្រឹងសមត្ថភាពទប់ទល់ស្ថានភាពអវិជ្ជមានរបស់ទីផ្សារតាមរយៈសកម្មភាពត្រួតពិនិត្យសមស្រប ។

**ប្រការ ៣.-**

ការអនុវត្តនិងសកម្មភាពត្រួតពិនិត្យលើមូលដ្ឋានហានិភ័យនិងទស្សនៈអនាគតពឹងផ្អែកលើលទ្ធផល នៃការវាយតម្លៃទម្រង់ហានិភ័យប្រចាំគ្រា និងគ្រប់ជ្រុងជ្រោយនៅកម្រិតគ្រឹះស្ថាននិងកម្រិតគួបសរុប បើចាំបាច់។

ការវាយតម្លៃទម្រង់ហានិភ័យ សំដៅដល់ការវិភាគគ្រប់ជ្រុងជ្រោយ អំពីស្ថានភាពរបស់គ្រឹះស្ថានដោយផ្អែកលើរាល់ទិន្នន័យនិងព័ត៌មាន ដែលត្រូវផ្តល់ជូនធនាគារជាតិនៃកម្ពុជា ។

ការវាយតម្លៃនេះ មានគោលបំណងវាយតម្លៃរាល់ហានិភ័យរបស់គ្រឹះស្ថាន ជាពិសេសហានិភ័យសាធនភាព សាច់ប្រាក់ងាយស្រួល ឥណទាន/សមភាគី ទីផ្សារនិងអត្រាការប្រាក់ ប្រសិទ្ធភាពនិងឯករាជ្យភាពនៃសវនកម្មនិងការត្រួតពិនិត្យផ្ទៃក្នុង បញ្ហាហានិភ័យ/អាជីវកម្ម/និងការផ្តល់មូលនិធិប្រមូលផ្តុំ ពិពិធកម្មសំពៀតឥណទាន ការកំណត់អត្តសញ្ញាណនៃភាពទន់ខ្សោយចំពោះសមត្ថភាពរបស់គ្រឹះស្ថាន ក្នុងការទប់ទល់នឹងការវិវត្តអវិជ្ជមាននៃទីផ្សារឬអាជីវកម្ម ការរៀបចំនិងប្រសិទ្ធភាពគ្រប់គ្រងហានិភ័យ ការចាត់ចែងបុគ្គលិកការបែងចែកភារកិច្ច និងទំនាស់ផលប្រយោជន៍ជាសក្តានុពល ឯករាជ្យភាពនៃមុខងារ "គន្លឹះ" ដូចជាការត្រួតពិនិត្យផ្ទៃក្នុងឬការប្រតិបត្តិតាម ប្រសិទ្ធភាពនៃបែបបទរាយការណ៍ នីតិវិធីនិងដំណើរការប្រគល់សិទ្ធិ/គណនេយ្យភាព ហេដ្ឋារចនាសម្ព័ន្ធនិងដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ប្រព័ន្ធគ្រប់គ្រងព័ត៌មាន អភិបាលកិច្ចសាជីវកម្មនិងប្រសិទ្ធភាពរបស់គណៈកម្មការដែលបានបង្កើត ការគាំទ្ររបស់ភាគទុនិក ផែនការយថាភាពសម្រាប់ដោះស្រាយហានិភ័យធំៗ នីតិវិធីនិងប្រសិទ្ធភាពនៃដំណោះស្រាយប៉ែកអាប់ (Back up) ដែលគាំទ្រដោយការធ្វើតេស្តទៀងទាត់ប្រចាំគ្រា ។

ជាពិសេស ការវាយតម្លៃនេះអាចអនុញ្ញាតឲ្យមានការកំណត់អត្តសញ្ញាណបានទាន់ពេលវេលានូវចំណុចខ្សោយចម្បងៗ និងបញ្ហាជាសក្តានុពល ដែលកើតឡើងដោយសារការគួបបញ្ចូលគ្នានូវហានិភ័យដែលអាចនាំឲ្យមានកត្តាងាយរងគ្រោះពីការប្រើប្រាស់ផ្នែកទ្រព្យអកម្មជាបំណុល ។

**ប្រការ ៤.-**

ធនាគារជាតិនៃកម្ពុជានឹងប្រើប្រាស់សេណារីយ៉ូ (Scenarios) និងវង្វាស់នៃការធ្វើស្ត្រេសតេស (Stress-testing measures) ក៏ដូចជាការប៉ាន់ប្រមាណផ្អែកលើរបកគំហើញនៃការត្រួតពិនិត្យ ដើម្បីធ្វើឲ្យប្រសើរឡើងនូវការវាយតម្លៃផ្អែកលើវង្វាស់ស្ត្រេសមេទ្រិក (Stress Metrics) ។ ការធ្វើស្ត្រេសតេស (Stress-testing) និងការប៉ាន់ប្រមាណនេះក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ ដើម្បីពិនិត្យអំពីប្រសិទ្ធភាពនៃផែនការយថាភាពជាពិសេស ដូចជា ផែនការផ្តល់មូលនិធិយថាភាព និងផែនការស្តារសាធនភាពនៅក្រោមស្ថានភាពឬការវិវត្តទីផ្សារជាអវិជ្ជមាន ជាដើម។

ក្នុងការអនុវត្តការវាយតម្លៃទម្រង់ហានិភ័យ ធនាគារជាតិនៃកម្ពុជា នឹងពិចារណាផងដែរអំពីការប្តេជ្ញារបស់ក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន ក្នុងការវាយតម្លៃឡើងវិញប្រចាំគ្រាលើប្រសិទ្ធភាពនៃគោលនយោបាយទទួលយកហានិភ័យ រចនាសម្ព័ន្ធចាត់តាំង ការរៀបចំ និងឯករាជ្យភាពនៃការត្រួតពិនិត្យផ្ទៃក្នុង ។ ការវាយតម្លៃឡើងវិញនេះ ត្រូវបានអនុវត្តជាពិសេស ក្នុងករណីៈ

ក. មានការប្រែប្រួលចម្បងចំពោះសកម្មភាពរបស់គ្រឹះស្ថាន ដូចជា សកម្មភាពថ្មី ហានិភ័យថ្មី និងប្រតិបត្តិការថ្មី

ខ. មានការប្រែប្រួលចម្បងនៅក្នុងរចនាសម្ព័ន្ធសាជីវកម្ម ដូចជា ការចូលភាគកម្ម ឬការបង្កើតបុត្តសម្ព័ន្ធឯកទេសថ្មី និង

គ. មានការវិវត្តអវិជ្ជមាននៃទីផ្សារ និងការប្រែប្រួលបរិស្ថានប្រកួតប្រជែង ដែលនាំឲ្យមានការដោះស្រាយនូវចំណុចខ្សោយជាសក្តានុពល នៅក្នុងផែនការយថាភាព។

**ប្រការ ៥.-**

ផ្អែកលើការវាយតម្លៃទម្រង់ហានិភ័យ ធនាគារជាតិនៃកម្ពុជា នឹងធ្វើការវិនិច្ឆ័យផ្អែកលើទស្សនៈអនាគត និងដោះស្រាយជាបន្ទាន់នូវបញ្ហាជាសក្តានុពលនៅក្នុងកម្រិតគ្រឹះស្ថាន និងក្នុងកម្រិតគួបសរុប បើចាំបាច់ ។ ធនាគារជាតិនៃកម្ពុជា នឹងដាក់ចេញវិធានការកែតម្រូវជាបន្ទាន់ចំពោះគ្រឹះស្ថាន បើចាំបាច់ ។ ការបង្គាប់ឲ្យអនុវត្តអធិបញ្ញាសម្រាប់ការអនុវត្តឲ្យមានប្រសិទ្ធភាពនូវវិធានការកែតម្រូវសមស្រប ចាំបាច់ត្រូវពិចារណាស្របតាមផលប៉ះពាល់ជាសក្តានុពលចំពោះស្ថិរភាពហិរញ្ញវត្ថុ ។

**ប្រការ ៦.-**

ធនាគារជាតិនៃកម្ពុជា នឹងពិចារណាដាក់ឲ្យអនុវត្តកាតព្វកិច្ចបង្កើនអនុបាតសាធនភាព ចំពោះគ្រឹះស្ថាន ឬក្រុមគ្រឹះស្ថានដែលមានទម្រង់ហានិភ័យក្នុងការប្រើប្រាស់ផ្នែកទ្រព្យអកម្មជាបំណុល ដែលមានកត្តាងាយរងគ្រោះធ្ងន់ធ្ងរ និង/ឬដែលអាចមានការគំរាមកំហែងធ្ងន់ធ្ងរចំពោះម្ចាស់ប្រាក់បញ្ញើ និងប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ។

កាតព្វកិច្ចបង្កើនអនុបាតសាធនភាពនេះជាការសម្រេចរបស់ធនាគារជាតិនៃកម្ពុជា ប៉ុន្តែ មិនត្រូវលើសពី ៣០ (សាបសិប) ភាគរយ នៃកាតព្វកិច្ចអនុបាតសាធនភាពអប្បរមា ដែលអនុវត្តចំពោះគ្រឹះស្ថានឡើយ ។

**ប្រការ ៧.-**

ធនាគារជាតិនៃកម្ពុជាអាចលើកលែងកាតព្វកិច្ចបង្កើនអនុបាតសាធនភាព លុះត្រាតែ ទម្រង់ហានិភ័យដែលបានវាយតម្លៃឡើងវិញនោះលែងជាកង្វល់នៃការត្រួតពិនិត្យក្រោយពីបានពិចារណាលើប្រសិទ្ធភាពនៃការអនុវត្តវិធានការកែតម្រូវ ។

កាតព្វកិច្ចបង្កើនអនុបាតសាធនភាពនៅកម្រិតគួបសរុបត្រូវបានជូនដំណឹងជាលាយលក្ខអក្សរចំពោះគ្រឹះស្ថាន និងមិនត្រូវជាផ្នែកមួយនៃកាតព្វកិច្ចបើកចំហរព័ត៌មាននោះទេ ។

**ប្រការ ៨.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានត្រួតពិនិត្យ អគ្គនាយកដ្ឋានបច្ចេកទេស អគ្គបេឡា អគ្គាធិការដ្ឋាន អង្គភាព និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០១១

**ទេសាភិបាល**

**ជា.ចាន់តូ**

<u>កន្លែងទទួល</u>

- ដូចប្រការ ៨
  "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

<u>ចម្លងជូន</u>

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# វិបត្តិបំណុលសាធារណៈប្រទេសក្រិច និងឥទ្ធិពលរបស់វាទៅលើសេដ្ឋកិច្ចពិភពលោក

វិបត្តិបំណុលសាធារណៈនៅក្នុងប្រទេសក្រិចបានបង្កបញ្ហានៅក្នុងទីផ្សារហិរញ្ញវត្ថុពិភពលោក ចាប់តាំងពីចុងឆ្នាំ២០០៩ ។ នៅក្នុងខែឧសភា ឆ្នាំ២០១០ ប្រទេសក្រិចបានក្លាយជាប្រទេសទីមួយក្នុងតំបន់អឺរ៉ុប ដែលស្នើសុំជំនួយហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុប និងពីមូលនិធិរូបិយវត្ថុអន្តរជាតិ (EU/IMF) ដែលមានតម្លៃដល់ទៅ ១១០ ពាន់លានអឺរ៉ូ ។ ទោះបីជាកញ្ចប់ថវិកាសង្គ្រោះបានដាក់អស់រយៈពេលជាងមួយឆ្នាំទៅហើយក៏ដោយ ក៏បំណុលសាធារណៈរបស់ប្រទេសក្រិចនៅតែមិនទាន់បានដោះស្រាយចេញនៅឡើយ ។ ដោយសារ ទី១)ការកើនឡើងនៃអត្រាការប្រាក់សញ្ញាប័ណ្ណរដ្ឋាភិបាល ដែលមានរយៈពេល២ឆ្នាំលើសពី ៣០០ពិន្ទុគោល ទី២)ការបន្តទម្លាក់ចំណាត់ថ្នាក់នៃមូលបត្ររដ្ឋាភិបាលដល់កម្រិតក្រោមចំណាត់ថ្នាក់វិនិយោគ ទោះបិតក្រោមកម្មវិធីជំនួយ EU/IMF និង ទី៣) ការកើនឡើងនៃស្វប់ឥណទាន (CDS) របស់ប្រទេសក្រិចដល់អត្រាខ្ពស់បំផុត ២៣,៥% (គិតត្រឹមថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០១១) ដែលបានបង្ហាញថា ភាពដែលមិនអាចសងបំណុលបានរបស់ប្រទេសក្រិចមានកម្រិត ៨៧% ក្នុងរយៈពេល៥ឆ្នាំខាងមុខ ។ បញ្ហាសំខាន់បំផុតគឺ វិបត្តិនៅប្រទេសក្រិចបានរីករាលដាលទៅកាន់ប្រទេសផ្សេងទៀតដូចជា ប្រទេសអៀឡង់និងព័រទុយហ្គាល់ដែលបានស្នើសុំជំនួយហិរញ្ញវត្ថុពីសហគមន៍អឺរ៉ុបនិងមូលនិធិរូបិយវត្ថុអន្តរជាតិនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១០ និងខែមេសា ឆ្នាំ២០១១ ជាបន្តបន្ទាប់ ។ បញ្ហាបំណុលសាធារណៈនេះ បានក្លាយជាហានិភ័យដ៏គួរឲ្យកត់សម្គាល់ចំពោះទីផ្សារហិរញ្ញវត្ថុនិងការងើបឡើងនៃសេដ្ឋកិច្ចពិភពលោក ។

## មូលហេតុនៃវិបត្តិបំណុលរបស់ប្រទេសក្រិច

បំណុលសាធារណៈស្ថិតក្នុងកម្រិតខ្ពស់ជាងធម្មតាចាប់តាំងពីឆ្នាំ១៩៨៩ ហើយត្រឹមចុងឆ្នាំ២០១០ បំណុលមានចំនួន ៣២៩ ពាន់លានអឺរ៉ូ ឬ ស្មើនឹង ១៤៨,២% នៃផលិតផលក្នុងស្រុកសរុប ។ ផលធៀបដ៏ខ្ពស់រវាងបំណុលសាធារណៈ និងផលិតផលក្នុងស្រុកសរុបនេះ គឺមានកម្រិតខ្ពស់ជាងកម្រិតអប្បបរមា (threshold) ដែលបានកំណត់ដោយសន្ធិសញ្ញា Maastricht ដែលចែងថា បំណុលសាធារណៈរបស់ប្រទេសសមាជិកមិនត្រូវលើសពី ៦០% នៃផលិតផលក្នុងស្រុកសរុបឡើយ ។ ប្រទេសក្រិចធ្លាប់ជួបប្រទះឱនភាពថវិកាយ៉ាងខ្លាំង ដែលមានចំនួន ១០,៥% នៃផលិតផលក្នុងស្រុកសរុបនៅចុងឆ្នាំ២០១០ ដែលខ្ពស់ជាងកម្រិតមធ្យមនៃតំបន់អឺរ៉ុបគឺ ៦% និងជាកម្រិតខ្ពស់ជាងគេក្នុងពិភពលោក ។

## វិបត្តិបំណុលសាធារណៈនៅក្នុងប្រទេសក្រិច ជាមូលដ្ឋានបណ្តាលមកពីកត្តាបួនរួមមាន៖

កត្តាទីមួយ គឺកង្វះខាតការត្រួតពិនិត្យផ្នែកសារពើពន្ធ ដោយសារគោលនយោបាយសុខុមាលភាពប្រជាជនដូចជា ប្រាក់បន្ថែមបីដងក្នុងមួយឆ្នាំ និងអាយុចូលនិវត្តន៍ ៥០ឆ្នាំ ដែលទាបជាងអាយុមធ្យមអន្តរជាតិ ហើយអត្ថប្រយោជន៍សោធននិវត្តន៍មិនស៊ីគ្នានឹងអាយុកាល ។ គោលនយោបាយបែបនេះ បាននាំឲ្យចំណាយសាធារណៈ ជាពិសេស ចំណាយទៅលើប្រាក់បៀវត្ស ប្រាក់សោធននិវត្តន៍ ឧបត្ថម្ភធនចាស់ជរានិងប្រាក់ឧបត្ថម្ភសម្រាប់និកម្មភាពមានចំនួនលើសពី ៧៥% នៃចំណាយសាធារណៈរបស់ក្រិច ។

កត្តាទីពីរ គឺភាពមិនស៊ីគ្នារវាងចំណូលនិងចំណាយរបស់រដ្ឋាភិបាល ។ ចំណាយសាធារណៈរបស់ប្រទេសក្រិច (មិនរាប់បញ្ចូលចំណាយការប្រាក់) មានចំនួន ៣២% នៃផលិតផលក្នុងស្រុកសរុប ខណៈដែលចំណូលថវិការដ្ឋ (មិនរាប់បញ្ចូលវិភាគទានសន្តិសុខសង្គម) មានត្រឹមតែ ២០% ប៉ុណ្ណោះ ។ ភាពខុសប្លែកគ្នានេះ មួយចំណែក គឺបណ្តាលមកពីអប្រសិទ្ធភាពនៃការប្រមូលពន្ធក៏ដូចជាការគេចពន្ធរបស់បុគ្គល ដែលមានចំណូលខ្ពស់ដែលជាហេតុធ្វើឲ្យមានឱនភាពថវិកា ។ ប្រទេសក្រិចត្រូវបង់ការប្រាក់ច្រើនដោយសារចំនួនកម្ចីច្រើនពីទីផ្សារហិរញ្ញវត្ថុក្នុងអំឡុងពេល១០ឆ្នាំមកនេះ ។ ក្នុងនាមជាសមាជិកនៃសហគមន៍អឺរ៉ុបក៏ជាកត្តាមួយដែលជំរុញឲ្យប្រទេសក្រិចខ្ចីក្នុងអត្រាការប្រាក់ទាប ។ អត្រាការប្រាក់រយៈពេលវែងរបស់ក្រិចនិងអត្រាការប្រាក់សញ្ញាប័ណ្ណរបស់រដ្ឋាភិបាលបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ បន្ទាប់ពីក្រិចបានក្លាយជាសមាជិកមួយរបស់សហគមន៍អឺរ៉ុប ។




កត្តាទីបី ភាពប្រកួតប្រជែងរបស់ក្រិចកំពុងធ្លាក់ចុះដោយសារប្រទេសផ្សេងទៀតក្នុងសហគមន៍អឺរ៉ុប។ កម្រិតប្រកួតប្រជែងរបស់ក្រិចបានធ្លាក់ចុះលើសពី ២៥% ចាប់តាំងពីខ្លួនបានចូលជាសមាជិកសហគមន៍អឺរ៉ុបនៅឆ្នាំ២០០០ ។ ថ្លៃឈ្នួលពលកម្មមធ្យម និងថ្លៃពលកម្មមួយឯកតានៅប្រទេសក្រិចខ្ពស់ជាងប្រទេសជាដៃគូនៅតំបន់អឺរ៉ុប ។ ទាំងនេះគឺជាឧបសគ្គចម្បងមួយចំពោះកំណើនសេដ្ឋកិច្ចដែលជះឥទ្ធិពលមិនល្អលើចំណូលពន្ធ ។

ចំណុចចុងក្រោយ គឺក្នុងអំឡុងពេលវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ២០០៨ រដ្ឋាភិបាលក្រិចបានធ្វើការចំណាយជាច្រើនដើម្បីជំរុញសេដ្ឋកិច្ច ដែលនាំឲ្យមានបន្ទុកហិរញ្ញវត្ថុដ៏ធំ និងការបាត់បង់ជំនឿទុកចិត្តរបស់វិនិយោគិនលើលទ្ធភាពសងបំណុលរបស់រដ្ឋាភិបាល ។ ចាប់តាំងពីចុងឆ្នាំ២០០៩ ប័ណ្ណបំណុលសាធារណៈរបស់ក្រិចត្រូវបានធ្លាក់ចំណាត់ថ្នាក់ជាបន្តបន្ទាប់រហូតស្ថិតក្រោមចំណាត់ថ្នាក់វិនិយោគ ដែលបង្កើនចំណាយការប្រាក់ (financing cost) និងបន្ថយលទ្ធភាពសងបំណុល ។

ដំណោះស្រាយរបស់សហគមន៍អឺរ៉ុបនិងមូលនិធិរូបិយវត្ថុអន្តរជាតិ បានផ្តោតជាសំខាន់ទៅលើហានិភ័យសាច់ប្រាក់ងាយស្រួលនៅក្នុងរយៈពេលមធ្យម ។ ក្នុងចន្លោះពេលពីបច្ចុប្បន្នទៅឆ្នាំ២០១៤ បន្ទាប់ពីពេលដែលខ្លួនត្រូវបង្កើនមូលនិធិពីទីផ្សារហិរញ្ញវត្ថុម្តងទៀត ប្រទេសក្រិចត្រូវបានរំពឹងថានឹងធ្វើរចនាសម្ព័ន្ធសេដ្ឋកិច្ចជាថ្មីក្រោមលក្ខខណ្ឌថវិកាសង្គ្រោះ (bailout conditionality) ដោយការអនុវត្តវិធានការហិរញ្ញវត្ថុតឹងរ៉ឹង (fiscal austerity measures) រួមមានការកាត់បន្ថយចំណាយសាធារណៈនិងបង្កើនចំណូល ដើម្បីបន្ថយឱនភាពហិរញ្ញវត្ថុ ។ ទោះជាយ៉ាងណាភាពអាចជឿជាក់បានលើកម្មវិធីនេះត្រូវបានចោទសួរ ជាពិសេសនៅ

ពេលប្រទេសក្រិចមិនអាចទទួលយកលក្ខខណ្ឌរបស់សហគមន៍អឺរ៉ុបឬមូលនិធិរូបិយវត្ថុអន្តរជាតិ ដោយសារសេដ្ឋកិច្ចបានធ្លាក់ចុះ ៤,៥% ដោយតម្រូវការក្នុងស្រុកធ្លាក់ចុះ ។ កញ្ចប់ថវិកា (financial package) ដែលជាដំបូងរំពឹងថានឹងបញ្ចប់នៅចុងឆ្នាំ២០១៣ ត្រូវបានពន្យារទៅមួយឆ្នាំទៀត ។ លើសពីនេះ ដោយសារចំណូលពីប័ណ្ណបំណុលរដ្ឋាភិបាល រយៈពេល២ឆ្នាំកើនឡើងគួរឲ្យកត់សម្គាល់ ក្រិចត្រូវតែប្រើថវិកាសង្គ្រោះម្តងទៀតដោយមិនអាចចៀសបាន។

ក្នុងភាពជាតំបន់អឺរ៉ុប ប្រទេសជាសមាជិកការពារការធ្លាក់ថ្លៃនៃរូបិយវត្ថុរបស់ខ្លួនតាមការអនុវត្តជាទូទៅរបស់ប្រទេសដែលទទួលបានជំនួយពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ជាលទ្ធផល ចំណូលជារូបិយប័ណ្ណរបស់ក្រិច ដែលទទួលបានមួយផ្នែកធំពីវិស័យទេសចរណ៍និងការដឹកជញ្ជូនជើងគោក ជើងទឹក ជើងអាកាសមិនបានកើនឡើងច្រើនទេ ។ វិនិយោគិនក៏បានចោទសួរផងដែរអំពីលទ្ធភាពសងបំណុលរបស់ក្រិច ចំពោះការពន្យារពេលកំណែទម្រង់ហិរញ្ញវត្ថុ ។

ថ្មីៗនេះ មានសំណើមួយអំពីការចូលរួមពីសំណាក់វិស័យឯកជននៅក្នុងការចែករំលែកបន្ទុកខ្លះតាមរយៈការបន្តជាថ្មីនៃប័ណ្ណបំណុលប្រទេសក្រិច (rollover of Greek bonds) ។ ទោះជាយ៉ាងណាអ្នកវិភាគជាច្រើនចាត់ទុកសំណើនេះ គ្រាន់តែជាការធ្វើឡើងរបស់ក្រិចដើម្បីទទួលបានពេលវេលាបន្ថែម ហើយមិនបង្កើតដំណោះស្រាយអ្វីឡើយ ។ ជាងនេះទៅទៀត សំណើនេះអាចចាត់ទុកជាកំហុសបច្ចេកទេសដោយភ្នាក់ងារផ្តល់ចំណាត់ថ្នាក់ឥណទាននិងអាចមានឥទ្ធិពលបង្កើតនូវវិបត្តិបំណុលមួយផ្សេងទៀត ។

**តារាង១: បំណុលបរទេសរបស់ធនាគារពាណិជ្ជ ចុងខែធ្នូ ឆ្នាំ២០១០**

| ប្រទេសផ្តល់ឥណទាន | | | | | | | |
|---|---|---|---|---|---|---|---|
| **ពាន់លាន USD** | **អាល្លឺម៉ង់** | **បារាំង** | **អង់គ្លេស** | **ហូឡង់** | **អាមេរិក** | **ប៊ែលស៊ិច** | **សរុប** |
| ព័រទុយហ្គាល | ៣៦,៤ | ២៦,៩ | ២៤,៣ | ៦,៥ | ៥,២ | ៣,៥ | **១០៣,0** |
| អៀរឡង់ | ១១៨,២ | ២៩,៦ | ១៣៥,២ | ១៦,៧ | 50.9 | ២៥,៤ | **៣៧៦,១** |
| អ៊ីតាលី | ៣៦,៤ | ២៦,៩ | ៦៦,៤ | ៤៥,៣ | 36.7 | ២៥,៨ | **៧២៩,១** |
| ក្រិច | ៣៤,0 | ៥៦,៧ | ១៤,១ | ៥,0 | ៧,៣ | ១,៩ | **១១០,0** |
| អេស្ប៉ាញ | ១៨១,៩ | ១៤០,៦ | ១០៧,២ | ៧៦,៩ | 47.2 | ២១,៥ | **៥៧៥,៣** |
| PIIGS | ៥៣២,៧ | ៦៤៦,៥ | ៣៤៧,២ | ១៥០,៥ | 147.5 | ៧៨,២ | **១.៩០២,៦** |

**កំណត់សម្គាល់ ៖** - PIIGS = ព័រទុយហ្គាល់ អៀឡង់ អ៊ីតាលី ក្រិច និងអេស្ប៉ាញ

## ឥទ្ធិពលដែលអាចកើតមានចំពោះសេដ្ឋកិច្ចសកលលោក

វិបត្តិបំណុលរបស់ប្រទេសក្រិចបានជះឥទ្ធិពលដោយផ្ទាល់ទៅលើប្រជាជនក្រិច ជាពិសេសតាមរយៈវិធានការរឹតបន្តឹងសារពើពន្ធ ។ ទោះបីជាមានស្ថាប័នជាច្រើនខិតខំប្រឹងប្រែងក្នុងការស្វែងរកដំណោះស្រាយមួយដ៏សមស្រប ប៉ុន្តែប្រសិនបើដំណោះស្រាយនោះមិនមានចីរភាពទេ វិបត្តិនេះអាចនឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទីផ្សារហិរញ្ញវត្ថុសកលនិងនៅទីបញ្ចប់អាចប៉ះពាល់ដល់សេដ្ឋកិច្ចពិភពលោកតាមរយៈចំណុចដូចខាងក្រោម ៖

**ជំនឿទុកចិត្តរបស់អ្នកវិនិយោគ ៖** ការធ្វើស្វប់នៃហានិភ័យឥណទាន (Credit default swap) នៃ PIIGS កើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងអំឡុងពេល ២ខែចុងក្រោយ ដែលធ្វើឲ្យថ្លៃហិរញ្ញប្បទាននៃប្រទេសដែលមានការអភិវឌ្ឍតិចតួចកើនឡើង ។ ការឡើងថ្លៃនៃកម្ចីជះឥទ្ធិពលអវិជ្ជមានដល់លទ្ធភាពក្នុងការសង ហើយ អាចនាំឲ្យមានការខកខានដល់ការសងបំណុល ។

**ទីផ្សារហិរញ្ញវត្ថុ ៖** ការប្រឈមជាមួយបំណុលរបស់ប្រទេសក្រិចនៃធនាគារពាណិជ្ជនៅក្នុងប្រទេសបារាំង និងអាល្លឺម៉ង់ក្នុងរូបភាពជាឥណទានបរទេសទៅកាន់វិស័យឯកជន និងសាធារណៈមានចំនួន សរុបប្រមាណ ៥៧ ពាន់លានដុល្លារអាមេរិក និង ៣៤ ពាន់លានដុល្លារអាមេរិករៀងគ្នា ដែលស្មើនឹង ១,៨% និង ១,២% នៃឥណទានបរទេសសរុប ។ ប្រសិនបើប្រទេសក្រិចមិនអាចសងបំណុលបានទេ ធនាគារពាណិជ្ជទាំងនោះនឹងអាចជួបប្រទះនូវការបាត់បង់មូលធន ហើយប្រសិនបើបញ្ហានេះរីករាលដាលដល់ប្រទេស PIIGS ភាពផុយស្រួយនៃបំណុល (Credit Crunch) អាចនឹងកើតមានឡើង ។ ជាងនេះទៅទៀត សញ្ញាប័ណ្ណរបស់ក្រិចភាគច្រើនត្រូវបានចេញផ្សាយនៅក្រោមច្បាប់របស់ក្រិច ដែលធ្វើឲ្យវិនិយោគិនបរទេសមានការលំបាកក្នុងការទារបំណុល ។

**តារាង២ : សមាសភាគនៃការនាំចេញ**

| | ប្រទេសនាំចេញ | | | | | | |
|---|---|---|---|---|---|---|---|
| % នៃការនាំចេញសរុប | EA-16 | EU-27 | អាមេរិក | ជប៉ុន | ចិន | Asia-7 | World |
| ក្រិច | 0.9 | 0.9 | 0.1 | 0.2 | 0.3 | 0.3 | 0.6 |
| ព័រទុយហ្គាល់ | 1.3 | 1.1 | 0.2 | 0.1 | 0.2 | 0.1 | 0.6 |
| អេស្ប៉ាញ | 4.7 | 4.3 | 0.9 | 0.6 | 1.5 | 0.9 | 2.6 |
| PIIGS | 13.0 | 12.9 | 3.2 | 1.9 | 4.1 | 2.5 | 7.8 |
| EA-16 | 57.9 | 51.4 | 16.0 | 10.8 | 15.6 | 9.0 | 29.3 |
| EU-27 | 66.5 | 66.8 | 21.2 | 14.1 | 20.5 | 12.6 | 38.1 |

**កំណត់សម្គាល់ ៖** - PIIGS = ព័រទុយហ្គាល់ អៀឡង់ អ៊ីតាលី ក្រិច និងអេស្ប៉ាញ -Asia-7= តៃវ៉ាន់ ថៃ កូរ៉េខាងត្បូង ឥណ្ឌូនេស៊ី ហ្វីលីពីន ហុងកុង និងសិង្ហបុរី

**ពាណិជ្ជកម្ម ៖** ប្រសិនបើបញ្ហានេះស្ថិតនៅក្នុង PIIGS ឥទ្ធិពលទៅលើសេដ្ឋកិច្ចសកលត្រូវបានរំពឹងថានៅមានកម្រិត ដោយសារតែការនាំចេញទៅកាន់ប្រទេសដែលមានការអភិវឌ្ឍតិចតួចមានត្រឹមតែ ៨% នៃការនាំចេញពិភពលោក ទោះបីជាពាណិជ្ជកម្មនៅក្នុងតំបន់សហគមន៍អឺរ៉ុបទទួលឥទ្ធិពលខ្លាំងជាងដោយសារតែការនាំចេញទៅ PIIGS មានចំនួន ១៣% នៃការនាំចេញសរុបក្នុងសហគមន៍អឺរ៉ុបក៏ដោយ ។ ប្រសិនបើប្រទេសឧស្សាហកម្មធំៗត្រូវបានប៉ះពាល់ ឥទ្ធិពលទៅលើសេដ្ឋកិច្ចសកលនឹងមានភាពធ្ងន់ធ្ងរ ព្រោះទីផ្សារអឺរ៉ុបមានទំហំស្មើនឹង ១/៣ នៃទីផ្សារសកល ។ ហេតុដូច្នេះ វិបត្តិបំណុលនៅប្រទេសក្រិចបង្កឲ្យមានហានិភ័យចំពោះសេដ្ឋកិច្ចសកល និងទីផ្សារហិរញ្ញវត្ថុពិភពលោក ប្រសិនបើគ្មានដំណោះស្រាយច្បាស់លាស់ ។

ចំពោះប្រទេសថៃវិញ ឥទ្ធិពលទៅលើសេដ្ឋកិច្ចថៃត្រូវបានសន្មតថាមានកម្រិត ដោយសារតែឥណទានហិរញ្ញវត្ថុរបស់វិនិយោគិនថៃ និងរបស់ស្ថាប័នហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចអឺរ៉ុបមានកម្រិតតិចតួច ។ តាមរយៈពាណិជ្ជកម្ម ឥទ្ធិពលនេះក៏នៅមានកម្រិតទាបដែរ ដោយសារតែការនាំចេញរបស់ប្រទេសថៃទៅកាន់ PIIGS មានចំនួន ១,៨% នៃការនាំចេញសរុបរបស់ថៃ ។ ទោះបីជាយ៉ាងណាក៏ដោយសេដ្ឋកិច្ចថៃនឹងទទួលឥទ្ធិពល

ដោយប្រយោលពីការប្រែប្រួលនៃអត្រាប្តូរប្រាក់និងទីផ្សារភាគហ៊ុននៅលើពិភពលោក។ ដោយសារតែវិបត្តិកំពុងរីករាលដាលឥទ្ធិពលនាពេលអនាគត គឺអាស្រ័យទៅលើភាពធ្ងន់ធ្ងរនិងកម្រិតនៃការរីករាលដាលនៃវិបត្តិនេះ។

# Greece's sovereign debt crisis and its impacts on the global economy

The sovereign debt crisis in Greece has been an issue in world financial markets since the end of 2009. In May 2010 Greece became the first euro-area country requesting a financial rescue from the European Union and International Monetary Fund (EU/IMF) worth €110 billion. Although it has been more than a year since the bailout, the public debt problem remained unresolved as attested by (1) the rise in Greece's two-year government bond yields of more than 300 basis points; (2) the continuous downgrade of Greek sovereign rating to below investment grade even under the EU/IMF program; and (3) the rise in Greece's credit default swaps (CDS) to a steep 23.5 percent (as of 14 July 2011), reflecting around 87 percent probability that Greece may default within the next five years. Most importantly, the Greece crisis has spread to other peripheral countries, namely Ireland and Portugal, which have also requested financial assistance from the EU and IMF in November 2010 and April 2011, respectively. This sovereign debt problem has become a significant risk to the world financial market and economic recovery.

### *Causes of the Greek debt crisis*

Greece's public debt has been at an elevated level since 1989 and as of the end of 2010 amounted to 329 billion or 148.2 percent of GDP. Such a high public debt to GDP ratio is almost three times larger than the threshold set by the Maastricht Treaty that stipulates. That public debt does not exceed 60 percent of the output for member countries. Greece has also experienced large fiscal deficit, which registered at 10.5 percent of GDP at the end of 2010 higher than the euro area average of 6.0 percent and one of the highest in the world.

The sovereign debt crisis in Greece is primarily caused by four factors. The first is the lack of fiscal discipline due to populist welfare policies, e.g., three-times-a-year bonuses as well as a minimum retirement age of 50, which is below the international average, and the attendant entitlement for pension benefits that is inconsistent with the average lifespan. Such policies led to increases in public spending, particularly on wages, pensions, elderly aids, and unemployment benefits, which accounted for more than 75 percent of Greece's public expenditures.




The second factor is the mismatch between government revenues and expenditures. Greece's public spending excluding interest payments accounted for 32 percent of GDP, while public revenues excluding social security contributions amounted to only 20 percent. This discrepancy is due partly to inefficient tax collection, as well as tax invasion particularly among high-income bracket individuals, resulting in ongoing fiscal deficits. Greece also needed to make substantial interest payments due to a large amount of borrowings from financial markets during the past ten years. Being a member of the European Union was also a factor that helped Greece to borrow cheaply. Greece's long-term interest rates and long-term government bond yields significantly declined after it became a member of the European Union.

Third, Greece's competitiveness is declining relative to its peers in the European Union. A measure of Greece's competitiveness has decreased by more than 25 percent since becoming an EU member in 2000. The average wage and unit labor cost in Greece were higher than its counterparts in the euro area. These were the main obstacle to economic growth that will also adversely affect on tax revenues.

Finally, during the global financial crisis in 2008, the Greek government spent extensively to stimulate the economy, contributing to the large fiscal burden and loss of investor confidence in the government's debt repayment ability. Since the end of 2009 Greek sovereign bonds' ratings were continuously downgraded to below investment grade, driving up financing costs and reducing the likelihood of paying back their debts.

### *Solutions to the sovereign debt crisis*

The EU/IMF solution to the Greek problem has been mainly focused on liquidity risks in the medium term. Between now and 2014, after which it would need to raise funds from the financial markets again, Greece is expected to restructure economy under the bailout conditionality by implementing fiscal austerity measures, including decreasing public expenditures and raising revenues to curtail fiscal deficit. Nonetheless, the credibility of the program has been questioned, particularly at the end of last year when Greece failed to achieve EU/IMF conditionality as the economy unexpectedly contracted by 4.5 percent owing to weak domestic demand. The financial package, initially expected to end in 2013, has thus been extended to end a

year later. In addition, given two-year government bond yields rose significantly, Greece inevitably requested for the second bailout.

Being a euro area member precludes the possibility of currency devaluation as generally practiced by countries that receive aid from the IMF. As a result, Greece's foreign currency earnings, which came mainly from tourism and maritime transportation, did not increase much. Investors also questioned Greece's ability to repay debts given the delayed fiscal consolidation.

Recently, there is a proposal for involvement of the private sector in sharing some burden through a rollover of Greek bonds. Nonetheless, many analysts view such a move only to buy Greece more time and not constitute the solution. Furthermore, this proposal could be regarded as a technical default by credit rating agencies and potentially trigger credit events.

**Table 1: Commercial Banks foreign claims as December 2010**

| Creditors countries | | | | | | | |
|---|---|---|---|---|---|---|---|
| **Billions USD** | **Germany** | **France** | **United Kingdom** | **Netherland** | **US** | **Belgium** | **Total** |
| Greece | 34.0 | 56.7 | 14.1 | 5.0 | 7.3 | 1.9 | **119.0** |
| Portugal | 36.4 | 26.9 | 24.3 | 6.5 | 5.2 | 3.5 | **103.0** |
| Ireland | 118.2 | 29.6 | 135.2 | 16.7 | 50.9 | 25.4 | **376.1** |
| Spain | 181.9 | 140.6 | 107.2 | 76.9 | 47.2 | 21.5 | **575.3** |
| Italy | 36.4 | 26.9 | 66.4 | 45.3 | 36.7 | 25.8 | **729.1** |
| PIIGS | 532.7 | 646.5 | 347.2 | 150.5 | 147.5 | 78.2 | **1,902.6** |

## *Potential impacts on global economy*

Greece's sovereign debt crisis directly affects its citizens, especially through fiscal-tightening measures. Despite many ongoing efforts from various institutions to find an appropriate solution, if comprehensive and sustainable solutions could not be reached, the crisis could have large impacts in global financial markets and could ultimately affect the world economy through the following channels:

**Investor confidence.** Credit default swaps of PIIGS rose significantly during the past two months, resulting in higher financing costs of those peripheral countries. Rising borrowing costs adversely affect ability to repay, potentially leading to default.

**Financial markets.** Exposures to Greek debts by commercial banks in France and Germany, in terms of ultimate foreign claims to public and private assets, total approximately $57 billion and $34 billion, which are equivalent to 1.8 and 1.2 percent of total foreign claims, respectively. If Greece defaults, those commercial banks will unavoidably face capital losses. If the problem spreads to other PIIGS countries, it can lead to credit crunch. Moreover, the majority of Greek bonds are issued under Greek law, which can make claims by foreign investors difficult.

**Table 2: Share of export** (By countries)

| **Exporting countries** | | | | | | | |
|---|---|---|---|---|---|---|---|
| **% to total exports** | **EA-16** | **EU-27** | **US** | **Japan** | **China** | **Asia-7** | **World** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Greece | 0.9 | 0.9 | 0.1 | 0.2 | 0.3 | 0.3 | 0.6 |
| Portugal | 1.3 | 1.1 | 0.2 | 0.1 | 0.2 | 0.1 | 0.6 |
| Spain | 4.7 | 4.3 | 0.9 | 0.6 | 1.5 | 0.9 | 2.6 |
| PIIGS | 13.0 | 12.9 | 3.2 | 1.9 | 4.1 | 2.5 | 7.8 |
| EA-16 | 57.9 | 51.4 | 16.0 | 10.8 | 15.6 | 9.0 | 29.3 |
| EU-27 | 66.5 | 66.8 | 21.2 | 14.1 | 20.5 | 12.6 | 38.1 |

**Note:** - PIIGS comprises Portugal, Ireland, Italy, Greece and Spain.
- Asia-7 consists of Taiwan, Thailand, South Korea, Indonesia, Philippines.Hong Kong and Singapore

**Trade.** If the problem is contained within PIIGS, the impact on the global economy is expected to be limited as exports to the periphery countries account for only 8 percent of world exports, although EU intra-regional trade would be more affected as exports to PIIGS account for 13 percent of total EU exports. If core countries become affected, impacts on the world economy would be severe because the European market accounts for one-third of world exports. The sovereign debt crisis in Greece thus poses a significant risk to the global economy and world financial markets if there is no concrete solution.

With regard to Thailand, the impact on the Thai economy is judged to be limited, as financial claims by Thai investors, including financial institutions, on European economies are minimal. The impact through trade is also marginal as Thai exports to PIIGS accounts for 1.8 percent of total Thai exports. Nonetheless, the Thai economy will be indirectly affected from volatilities in foreign exchange and stock markets worldwide. As the crisis is unfolding, future impacts will largely depend on the severity and the degree of contagion of the problem.

***************************

## តារាង: អត្រាប្តូរប្រាក់ប្រចាំខែ (ចុងខែ)

| ចុងខែ | អត្រាទីផ្សារ | | | | | អត្រាផ្លូវការ | | | | | គម្លាតអត្រាមធ្យម | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | អត្រា ទិញ | អត្រា លក់ | អត្រា មធ្យម | បម្រែបម្រួលប្រចាំខែ | | អត្រា ទិញ | អត្រា លក់ | អត្រា មធ្យម | បម្រែបម្រួលប្រចាំខែ | | ( អត្រាផ្លូវការ-អត្រាទីផ្សារ) | |
| | | | | +/- | % | | | | +/- | % | | |
| **2009** | | | | | | | | | | | | |
| Jan-មករា | 4,125 | 4,139 | 4,132 | -17.00 | -0.41 | 4,112 | 4,120 | 4,116 | -35.00 | -0.86 | -16.00 | -0.39 |
| Feb-កុម្ភៈ | 4,123 | 4,135 | 4,129 | 2.00 | 0.05 | 4,122 | 4,130 | 4,126 | -10.00 | -0.24 | -3.00 | -0.07 |
| Mar-មីនា | 4,093 | 4,104 | 4,099 | 30.00 | 0.73 | 4,089 | 4,097 | 4,093 | 33.00 | 0.80 | -5.50 | -0.13 |
| Apr-មេសា | 4,131 | 4,135 | 4,133 | -38.00 | -0.93 | 4,117 | 4,125 | 4,121 | -28.00 | -0.68 | -12.00 | -0.29 |
| May-ឧសភា | 4,143 | 4,154 | 4,149 | -12.00 | -0.29 | 4,137 | 4,145 | 4,141 | -20.00 | -0.49 | -7.50 | -0.18 |
| Jun-មិថុនា | 4,182 | 4,197 | 4,190 | -39.00 | -0.94 | 4,160 | 4,168 | 4,164 | -23.00 | -0.56 | -25.50 | -0.61 |
| Jul-កក្កដា | 4,244 | 4,263 | 4,254 | -62.00 | -1.48 | 4,187 | 4,195 | 4,191 | -27.00 | 0.65 | -62.50 | -1.49 |
| Aug-សីហា | 4,175 | 4,186 | 4,181 | 69.00 | 1.63 | 4,142 | 4,150 | 4,146 | 45.00 | 1.07 | -35.00 | -0.84 |
| Sep-កញ្ញា | 4,216 | 4,226 | 4,221 | -41.00 | -0.98 | 4,172 | 4,180 | 4,176 | -30.00 | -0.72 | 55.00 | 1.32 |
| Oct-តុលា | 4,193 | 4,203 | 4,198 | 23.00 | 0.55 | 4,170 | 4,178 | 4,174 | 2.00 | -0.05 | -23.00 | -0.60 |
| Nov-វិច្ឆិកា | 4,164 | 4,171 | 4,168 | 29.00 | 0.70 | 4,159 | 4,167 | 4,163 | 11.00 | -0.26 | -5.00 | -0.12 |
| Dec-ធ្នូ | 4,181 | 4,190 | 4,186 | -17.00 | -0.41 | 4,165 | 4,173 | 4,169 | -6.00 | -0.14 | -17.00 | -0.39 |
| **2010** | | | | | | | | | | | | |
| Jan-មករា | 4,185 | 4,193 | 4,189 | -4.00 | -0.09 | 4,167 | 4,175 | 4,171 | -2.00 | -0.04 | -18.00 | -0.43 |
| Feb-កុម្ភៈ | 4,194 | 4,201 | 4,198 | -9.00 | -0.21 | 4,183 | 4,191 | 4,187 | -16.00 | -0.38 | -11.00 | -0.25 |
| Mar-មីនា | 4,189 | 4,195 | 4,192 | 5.00 | 0.11 | 4,182 | 4,190 | 4,186 | 1.00 | 0.02 | -6.00 | -0.14 |
| Apr-មេសា | 4,217 | 4,228 | 4,223 | 28.00 | 1.00 | 4,200 | 4,208 | 4,204 | 18.00 | 1.00 | -19.00 | -0.44 |
